# ព្រះជីវប្រវត្តិ សម្តេចព្រះសង្ឃរាជ



## គណៈមហានិកាយ និង គណៈធម្មយុត្តិនិកាយ

ពិធីបុណ្យខួប ៣៥វស្សា នៃថ្ងៃសោយទីវង្គតរបស់

សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន ណាត

១៤កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស២៥១៣

គ.ស១៩៦៩

១៤កើត ខែភទ្របទ ឆ្នាំវក ឆស័ក ព.ស២៥៤៨

គ.ស២០០៤

## រៀបរៀងដោយ

ភិក្ខុបញ្ញាវិមលោ លឹម ទាសនា

ចៅអធិការស្តីទីវត្ត អង្គប្រិយសិរីមានជ័យ

## កែសំរួលដោយ

ភិក្ខុ គឹម សំបូរ

ចៅអធិការវត្ត ស្លំប្រាំពីរ

## រចនារូប

លោក ប៊ុន សារិន (ហាងកែរូបថតសាមគ្គី)

លោក ទន្យ សុធារម្យ (ហាងកែរូបថតសាមគ្គី)



ឆ្នាំ ២០០៤

# អារម្ភកថា

សម្តេចព្រះសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត ជាមហាថេរៈអក្សរសាស្ត្រខ្មែរ ហើយក៏ជាមហាកវីដែលធ្លាប់មានកិត្តិស័ព្ទល្បីរន្ទឺលើលោកផងដែរ។ ព្រះអង្គបានបន្សល់ទុកនូវស្នាព្រះហស្តដ៏បវរសម្រាប់ការសិក្សានៃកុលបុត្រកុលធីតា និង ជនានុជនខ្មែរគ្រប់ៗរូប ។

ដើម្បីឧទ្ទិសដល់គុណូបការៈដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំព្រះករុណាខ្ញុំមានបំណងបោះពុម្ពឡើងវិញនូវជីវប្រវត្តិរបស់ព្រះអង្គដែលជាឯកសាររៀបរៀងដោយព្រះមុនីកោសល្យ សួរ ហាយ ដើម្បីទុកជាធម្មទានប្រគេនជូនព្រះករុណាគ្រប់ព្រះអង្គ កុលបុត្រ កុលធីតា និងជនានុជនគ្រប់ៗរូប សម្រាប់ការសិក្សាស្វែងយល់ និងចងចាំពីឧត្តមភាព ពីស្នាព្រះហស្ត និង ព្រះរាជបេសកកម្មរបស់ព្រះមហាថេរៈអក្សរសាស្ត្រខ្មែរមួយព្រះអង្គ ដែលកិត្តិនាមតែងតែស្ថិតស្ថេរជាអមតៈលើលោកនេះ ជាពិសេស គឺស្ថិតក្នុងសតិវិញ្ញាណនៃព្រលឹងកូនខ្មែរ ។

សូមឧទ្ទិសមហាកុសលនេះ ជូនលោក ឃុយ សៀន អភិបាលស្រុកកំពត លោក ខឿ សារមេត ប្រធានមន្ទីធម្មការសាសនាខេត្តកំពត លោក ហុង ឥមហេង មន្ត្រីគយ និងរដ្ឋករខេត្តកំពត ព្រមទាំងពុទ្ធបរិស័ទជាច្រើនរូបទៀត ដែលពុំអាចរៀបរាប់ឈ្មោះអស់នៅទីនេះ ជាអ្នកបានរួមកុសលជួយឧបត្ថម្ភ ចំពោះខ្ញុំព្រះករុណា អាត្មាភាពក្នុងការបោះពុម្ពឡើងវិញ នូវព្រះរាជជីវប្រវត្តិសម្តេចព្រះមហាសុមេធា

ធិបតី ជោតញ្ញាណោ **ជួន ណាត** ដូចដែលកំពុងស្ថិតក្នុងព្រះហស្ត និង ក្នុងដៃនៃព្រះករុណាគ្រប់ព្រះអង្គ និង កុលបុត្រ កុលធីតា ព្រមទាំងជនានុជនខ្មែរគ្រប់ៗរូប នាបច្ចុប្បន្ន ៕

វត្តអង្គប្រិយ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៨

ចៅអធិការស្តីទី

ភិក្ខុបញ្ញាវិមលោ **លឹម នាសនា**



សម្តេចព្រះមហាសង្ឃរាជ គណៈមហានិកាយ

**និល ទៀង**

# ១.សម្តេចព្រះមហាសង្ឃរាជ

## ព្រះនាម និល ទៀង

## គណៈមហានិកាយ

ព.ស ២៤០១-២៤៥៧

គ.ស ១៨៥៧-១៩១៣

-ព្រះអង្គទ្រង់ប្រសូត នៅថ្ងៃសៅរ៍ ៧កើត ខែអាសាឍ ឆ្នាំវក ឆស័ក ព.ស ២៣៦៨ គ.ស ១៨២៤ ក្នុងស្រុកពោធិព្រះបាទ ខេត្តគៀនស្វាយ (ស្រុកគៀនស្វាយ ខេត្តកណ្តាល បច្ចុប្បន្ន) ។ព្រះអង្គ ជាបុត្រច្បង នៃបិតា នាម និល មាតា នាម ឡឹក ។

-ក្នុងគ.ស ១៨៣១ កាលនោះកុមារ**ទៀង** ទើបតែអាយុបាន៨ឆ្នាំ ទ័ពយួន និងសៀមបានពើបប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា នៅតំបន់គៀនស្វាយ ដើម្បីដណ្តើមយកស្រុកខ្មែរ ។ គ្រួសារសម្តេច **ទៀង** ទាំងប៉ុន្មាន ត្រូវ ទ័ពសៀមចាប់កេណ្ឌកៀរយកទៅស្រុកសៀម ទុកធ្វើជាទាសាទាសី ។ កុមារ**ទៀង**និងជីដូន ត្រូវគេបញ្ជូនអោយទៅរស់នៅ ឯទីក្រុងបាងកក ។ នៅទីនោះ កុមារ**ទៀង** បានជួបនឹងមាម្នាក់ឈ្មោះ ពៅ ជាអាមាត្យ របស់ព្រះបាទ សម្តេចព្រះ **អង្គឌួង** កាលព្រះអង្គនៅជាព្រះអង្គម្ចាស់ដែល សៀមកេណ្ឌកៀរយកទៅធ្វើជាឈ្លើយដែរ ។ ចំណែកគ្រួសារសម្តេច មួយផ្នែកទៀត ត្រូវសៀមបញ្ជូនទុកអោយរស់នៅ ស្រុកមង្គលបុរី ក្នុង ខេត្តបាត់ដំបង ។

-ព្រះអង្គមានព្រះជន្មាយុបាន ១១ឆ្នាំ ក្នុងឆ្នាំ មមី ឆស័ក ព.ស ២៣៧៨ គ.ស ១៨៣៤ បានបំពេញផ្នួសជាសាមណេរ នាវត្តមួយ នៅទីក្រុងបាងកក ។

-ព្រះជន្មាយុ បាន ២១វស្សា ក្នុងឆ្នាំរោង ព.ស ២៣៨៨ គ.ស ១៨៤៤ សម្តេច ព្រះ**ណាំក្លាវ** ព្រះចៅក្រុងសៀម ទ្រង់ព្រះរាជានុញ្ញាត អោយសាមណេរ **ទៀង** ចូលបំពេញឧបសម្បទា ក្នុងនាគខ្លានព្រះរាជទ្រព្យ នៅវត្តព្រះស្រីរតនសាស្តារារាម គឺ **វត្តព្រះកែវមរកត ក្រុងបាងកក** ។

-ព្រះជន្មាយុបាន ២៦វស្សា ក្នុងឆ្នាំរកា ឯកស័ក ព.ស ២៣៩៣ គ.ស ១៨៤៩ ព្រះអង្គបានទៅថ្វាយ ព្រះពរលាសម្តេចព្រះ**ណាំក្លាវ** ត្រឡប់មកប្រទេសកម្ពុជាវិញ ។ លុះមកដល់ប្រទេសកម្ពុជាហើយ ព្រះបាទហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង** ទ្រង់សូមនិមន្តអោយគង់នៅប្រទេសកម្ពុជា ហើយទ្រង់បានធ្វើព្រះរាជសុភអក្សរ ថ្វាយសម្តេចព្រះ **ណាំក្លាវ** ។

-ព្រះជន្មាយុបាន ៣៤វស្សា ក្នុង ឆ្នាំម្សាញ់ នពស័ក ព.ស ២៤០១ គ.ស ១៨៧៥ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង** ទ្រង់បានលើកព្រះព្រហ្មមុនី **និល ទៀង** អោយគ្រងទីសម្តេចព្រះមហាសង្ឃរាជា ក្រុងកម្ពុជា ។

លុះរំលងពីនោះមក បានមួយឆ្នាំ ព.ស ២៤០២ គ.ស ១៨៥៨ ព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង** បានតាំងសម្តេចព្រះមហាសង្ឃរាជ **និល ទៀង** ជាស្តេចសង្ឃពេញទី ហើយបានរៀបចំពិធីថ្វាយទឹកក្លស់ទឹកស័ង្ខ នៅក្រុងឧត្តុង្គមានជ័យ មានគោរម្យងារជា "**សម្តេចព្រះមហាសង្ឃរាជា គណាធិបតី សិរីបរមបពិត្រ ជាសង្ឃនាយកតិលកលោកាចរិយោត្តមបរមមេធសង្ឃជេដ្ឋា មហាសង្ឃរាជា ធម្មិកចរោត្តមបរមបពិត្រដ៏ជាអធិបតីព្វដ៏គណសង្ឃក្នុងក្រុងកម្ពុជា ជេដ្ឋារដ្ឋាមហាឥន្ទបត្តនគរបវរបុរីរម្យឧត្តមរាជបនិជាមហាមគ្គនាយក**" សំរេចកិច្ចអស់ទ្រទ្រង់សង្ឃព្រះរាជាគណៈទាំង៤សំរាប់ ។

សម្តេចព្រះមហាព្រះសង្ឃរាជ **និល ទៀង** ព្រះអង្គមានឋានន្តរស័ក្តិមហាសង្ឃរាជ នៅក្នុងរាជ្យ ៣គឺ :

១. ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង**

២. ព្រះបាទសម្តេចព្រះ **នរោត្តម** ព្រះចៅក្រុងកម្ពុជាធិបតី

៣. ព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ** ព្រះចៅក្រុងកម្ពុជាធិបតី ។

-ព្រះជន្មាយុបាន៩០វស្សាគត់ នៅក្នុងឆ្នាំឆ្លូវ ព្រះអង្គទ្រង់សោយទីវង្គត នៅថ្ងៃព្រហស្បតិ៍ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ បញ្ចស័ក ព.ស ២៤៥៧ ត្រូវនឹងថ្ងៃទី២ ខែតុលា គ.ស ១៩១៣ វេលាម៉ោង ១២និង

៤០នាទី អាធ្រាត្រ ដោយព្រះរោគជរាពាធ នៅព្រះរាជតំណាក់វត្ត ឧណ្ណាលោម ក្រុងភ្នំពេញ ។



សម្ដេចព្រះធម្មលិខិត គណៈមហានិកាយ

ហ៊ែ អ៊ុក

## ២.សម្តេចព្រះធម្មលិខិត សិរីមហាសង្ឃកិច្ច

## ឥន្ទត្ថេរោ កែ អ៊ុក ព្រះសង្ឃនាយក

## គណៈមហានិកាយ

## ព.ស ២៤៥៨-២៤៨០

## គ.ស ១៩១៤-១៩៣៦

-ព្រះអង្គប្រសូត នៅថ្ងៃព្រហស្បតិ៍ (បាត់រនោច. ខ្មើត) ខែកត្តិក ឆ្នាំកុរ ត្រីស័ក ព.ស ២៣៩៥ គ.ស ១៨៥១ នៅភូមិក្រោលខៀវ ស្រុកពញាឮ ខេត្តកណ្តាល ។ បិតា នាម កែវ មាតា នាម មា ហើយត្រូវ ជាចៅសម្តេច **ជហ្វា ម៉ុក** ។

-មានព្រះជន្មាយុបាន ១០ឆ្នាំ នៅឆ្នាំវក ត្រីស័ក ព.ស ២៤០៤ គ.ស ១៨៦០ មាតាបិតានាំយកទៅរៀនសូត្រនៅវត្តរំដួល ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នៅក្នុងសំណាក់ **ព្រះពោធិវង្ស ប្រាក់** ។

-មានព្រះជន្មាយុ ១៥ឆ្នាំ ក្នុងឆ្នាំឆ្លូវ សប្តស័ក ព.ស ២៤០៩ គ.ស ១៨៦៥ បានបួសជាសាមណេរ នៅវត្តរំដួល ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

-មានព្រះជន្មាយុ ២២វស្សា នៅក្នុងឆ្នាំវក ចត្វាស័ក ព.ស ២៤១៦ គ.ស ១៨៧២ បានបំពេញឧបសម្បទាជាភិក្ខុ នៅវត្តឧណ្ណាលោម ដែលមានសម្តេចព្រះសង្ឃរាជ **និល ទៀង** ជាព្រះឧបជ្ឈាយ៍ ។

-ព្រះជន្មាយុ ៦៤វស្សា នៅក្នុងឆ្នាំខាល ឆស័ក ព.ស ២៤៥៨ គ.ស ១៩១៤ ព្រះអង្គបានទទួលសមណស័ក្តិ ជា **ព្រះសង្ឃនាយកស្ដីទី** ។

-ព្រះជន្មាយុ ៧៩វស្សា នៅក្នុងឆ្នាំរោង សំរឹទ្ធិស័ក ព.ស ២៤៧២ គ.ស ១៩២៨ ព្រះអង្គបានទទួលសមណស័ក្តិជា **សម្ដេចព្រះធម្មលិខិតសង្ឃនាយក សិរីមហាសង្ឃកិច្ច គណៈមហានិកាយ** (**ព្រះសង្ឃនាយកស្ដីទី** ចំនួន ១៥ឆ្នាំ) ។

-ព្រះជន្មាយុ ៨៦វស្សា នៅក្នុងឆ្នាំជូត អដ្ឋស័ក ព.ស ២៤៨០ គ.ស ១៩៣៦ ព្រះអង្គបានចូលទីវង្គត នៅថ្ងៃសៅរ៍ ២រោច ខែ ជេស្ឋ ឆ្នាំជូត នៅវេលា ម៉ោង ២០ និង៣០នាទី នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។



សម្ដេចព្រះមហាសុមេធាធិបតី គណៈមហានិកាយ

ប្រាក់ ហ៊ិន

# ៣.សម្តេចព្រះមហាសុមេធាធិបតី

## ប្រាក់ ហ៊ិន

## ព្រះសង្ឃនាយក គណៈមហានិកាយ

## ព.ស ២៤១៨-២៤៩១

## គ.ស ១៩៣៧-១៩៤៧

-ព្រះអង្គប្រសូត នៅថ្ងៃអាទិត្យ ៨កើត ខែ បុស្ស ឆ្នាំកុរ បញ្ចស័ក ព.ស២៤០៤ គ.ស ១៨៦៣ នៅភូមិចាក់អង្ករ ស្រុកកំពង់សៀម ខេត្តកំពង់ចាម (តែពេលទំងន់ នៅភូមិពោធិជំទាវមាន់ ខេត្តព្រៃវែង ដោយស្រុកមានវិបត្តិភ័ន្តប្រែជាន់រាមាកំហែង ក៏បានរត់ទៅនៅភូមិចាក់អង្ករវិញ) ។ បិតានាម ប្រាក់ ជាជំទប់លេខ១ មាតានាម ដែង ក្រោយមក មាតាបិតា បានមករស់នៅឃុំលេខ៦ ជ្រោយចង្វា ភ្នំពេញ មានរបរជាអ្នកជំនួញឫស្សី ។

-ព្រះជន្មាយុបាន ១២ឆ្នាំ បានបួសជាសាមណេរនៅវត្តសាំងសាមី ក្រុងព្រៃវែង ពីឆ្នាំចរ ឆស័ក ព.ស២៤១៨ គ.ស ១៨៧៤ ។

-ព្រះជន្មាយុបាន ២១វស្សា បានឧបសម្បទាជាភិក្ខុ នៅក្នុងវត្តសាំងសាមី ឆ្នាំមមែ ចត្វាស័ក ព.ស២៤២៧ គ.ស ១៨៨៣ ព្រះឧបជ្ឈាយ៍អោយនាមបញ្ញត្តិថា **សុធម្មត្ថេរ** ។

-ព្រះអង្គបានឡើងជាចៅអធិការវត្តសារាវ័នតេជោ ឃុំលេខ៣ ក្រុងភ្នំពេញ ពីឆ្នាំចរ ត្រីស័ក ព.ស ២៤៥៤ គ.ស ១៩១០ ។

-ព្រះជន្មាយុ ៧៩វស្សា នៅក្នុងឆ្នាំឆ្លូវ ព.ស ២៤៨១ ព្រះអង្គបាន ឡើងជា **ព្រះសង្ឃនាយករស្តីទី** គណៈមហានិកាយ (ព្រះរាជក្រឹត្យ លេខ ៦ ចុះថ្ងៃទី ០១ ខែ ហ្វេវ្រីយេ ឆ្នាំ១៩៣៧)

-ព្រះជន្មាយុ ៧៧វស្សា ព្រះអង្គបានទទួលឋានន្តរស័ក្តិ ជាព្រះសង្ឃនាយក (ព្រះរាជ ក្រឹត្យលេខ ២២ ចុះថ្ងៃទី ១៧ ដេសមប្រី ឆ្នាំ ១៩៤០) ។

-ព្រះជន្មាយុ ៨០វស្សា ព្រះអង្គបានឡើងសមណស័ក្តិជាន់ខ្ពស់ជាទី **សម្តេចព្រះពោធិវង្ស** ព្រះសង្ឃនាយកគណៈមហានិកាយ នៅថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំមមី ចត្វាស័ក ព.ស ២៤៧៤ គ.ស ១៩៣០ ។

-មានព្រះជន្មាយុ៨១វស្សា ព្រះអង្គបានឡើងសមណស័ក្តិខ្ពស់បំផុត ជាទី **សម្តេចព្រះមហាសុមេធាធិបតី** សង្ឃនាយក គណៈមហានិកាយ នៅថ្ងៃ ១រោច ខែអស្សុជ ឆ្នាំមមែ បញ្ចស័ក ព.ស២៤៧៥ ត្រូវនឹងថ្ងៃ១៩ ឧកតូប្រី ឆ្នាំ ១៩៣១ ។

-មានព្រះជន្មាយុ ៨៥វស្សា ព្រះអង្គបានចូលទីវង្គត នៅថ្ងៃព្រហស្បតិ៍ ៨កើត ខែកក្តិក ឆ្នាំកុរ ព.ស២៤៩១ ត្រូវនឹងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ វេលាពាក់កណ្តាលអាធ្រាត្រ ។



សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ

ជួន ណាត ជោតញ្ញាណោ

## ៤.សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ

## ជួន ណាត ជោតញ្ញាណោ

### ១- ជាតិបរិច្ឆេទ កំណត់អំពីជាតិ

**សម្តេចព្រះសង្ឃរាជ** ទ្រង់ប្រសូតនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំវកឆស័ក ព. ស.២៤២៧ គឺថ្ងៃទី១១ ខែមីនា គ.ស. ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ សម្តេចមានព្រះជាតិក្នុងត្រកូលកសិករ ព្រះមាតាសម្តេច នាម **យក់** ព្រះបិតានាម **ព្រហ្ម ជួន** ។ គ្រួសារនេះមានបុត្រតែពីរនាក់គឺ អង្គសម្តេច ព្រះសង្ឃរាជ និងលោកអ្នកឧកញ៉ាសោភណមន្ត្រី **ជួន នុត** ជាព្រះអនុជនៃសម្តេចព្រះសង្ឃរាជ ។

### ២- កុមារបរិច្ឆេទ កំណត់អំពីភាពនៃកុមារ

សម្តេចកាលនៅកុមារភាព មានព្រះជន្មាយុរវាង១២ឆ្នាំ ព្រះមាតាបិតាបាននាំយកទៅផ្ញើផ្ទាក់អោយរៀនសូត្រអក្សរសាស្ត្រ របស់ជាតិក្នុងសំណាក់លោកគ្រូសូត្រស្តាំនាម **កែ ម៉ម** វត្តពោធិព្រឹក្ស ហៅវត្ត (ពោល្យំ) សង្កាត់រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

### ៣-បព្វជ្ជាបរិច្ឆេទ កំណត់អំពីបព្វជ្ជា

លុះសម្តេចមានព្រះជន្មាយុ១៤ឆ្នាំ បានបួសជាសាមណេរក្នុងថ្ងៃ១៥កើត ខែពិសាខ ឆ្នាំចរសំរឹទ្ធស័ក ព.ស.២៤៤១ គ.ស. ១៨៩៧

នៅបំពេញចូសិក្សានៅវត្តពោធិព្រឹក្ស អស់រយៈកាល ២ឆ្នាំ ទើបចេញពីវត្តពោធិព្រឹក្សទៅរៀនសូត្រ ព្រះបរិយត្តិធម៌ឯវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងសំណាក់ព្រះគ្រូ **ទេព សោ** នាកុដិថៃវ ប្រឋកំពែងខាងជើង ក្នុងកាល ព.ស.២៤៤៣ គ.ស.១៨៩៩/ ។

## ៤-ឧបសម្បទាបរិច្ឆេទ កំណត់អំពីឧបសម្បទា

/សម្តេចលុះបានព្រះជន្មាយុគម្រប់២១វស្សា បានទ្រង់និមន្តត្រឡប់ទៅសូមឧបសម្បទាជាភិក្ខុក្នុងវត្តពោធិព្រឹក្ស ដែលជាវត្តដើមវិញ ដោយមានព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ **ម៉ា កេត** សុវណ្ណប្បញ្ញោ ជាព្រះឧបជ្ឈាយ៍ កាលលោកនៅជាចៅអធិការវត្ត ពោធិព្រឹក្ស មានព្រះតេជព្រះគុណ **កែ ម៉ម** មិស្សនាគោ ជាគ្រូសូត្រស្តាំ និង ព្រះតេជគុណ **អ៊ុន ខឹម** តិក្ខប្បញ្ញោ ជាគ្រូសូត្រឆ្វេង សូត្របំពេញកិច្ចឧបសម្បទា នៅថ្ងៃ ១៥កើត ខែជេស្ឋ ឆ្នាំរោងឆស័ក ព.ស. ២៤៤៨ គ.ស.១៩០៤ ។ សម្តេចទ្រង់ទទួលព្រះនាមបញ្ញត្តិថា **ជោតញ្ញាណោ** លុះទ្រង់បំពេញឧបសម្បទាជាភិក្ខុភាពរួចហើយ ទ្រង់ក៏និមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោម ទទួលការសិក្សាគន្ថធុរៈវិញទៀត/។

## ៥-បរិយត្តិបរិច្ឆេទ កំណត់អំពីការសិក្សា

/ **សម្តេចព្រះសង្ឃរាជ** មានសេចក្តីព្យាយាមប្រកបដោយថាមពលដ៏ក្លៀវក្លា ក្នុងការសិក្សា ទាំងផ្នែកភាសាបាលី ទាំងផ្នែកគាសាឯទៀត មានភាសាបារាំង

ជាដើម ។ ការសិក្សារបស់ព្រះសង្ឃរាជ មានជោគជ័យប្រសើរណាស់ បណ្ដាលោកអ្នកសិក្សាក្នុងសម័យនោះក្នុងជំនាន់ជាមួយគ្នានឹងសម្ដេច ព្រះសង្ឃរាជ ឃើញមានតែសម្ដេចព្រះសង្ឃរាជ ដែលរៀនចម្រើនលូតលាស់ មានល្បឿនឈ្នះលោកឯទៀត ។ សម្ដេចចាប់រៀនដំបូង មេសូត្រ ប្រែមូលកច្ចាយនៈ នឹងគម្ពីរធម្មបទ អំពីព្រះពុទ្ធឃោសាចារ្យព្រះនាម **ម៉ា កេត** ដែលមានព្រះឧបជ្ឈាយ៍នៃសម្ដេចព្រះសង្ឃរាជ ។

សម្ដេចព្រះសង្ឃរាជ ពេលដែលទ្រង់ចាប់រៀនវិជ្ជាណាមួយ មានបាលីជាដើម គឺរៀនដោយយកព្រះទ័យទុកដាក់ ខំប្រឹងប្រែង ឥតមានបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ ។ សម្ដេចទ្រង់ទទួលការសិក្សានោះគឺ សិក្សាដោយឆន្ទៈ ដ៏មានកំលាំងមែនទែន ពុំសិក្សាវិជ្ជា ណាមួយដោយលេងៗទេ ។ វិជ្ជាខាងភាសាបាលី ភាសាសំស្ក្រឹត និង ភាសាបារាំង សុទ្ធតែវិជ្ជាដែលប្រដាប់ដោយវេយ្យាករណ៍ហ្មត់ចត់ជ្រាលជ្រៅ លំបាករៀនលំបាកយល់ជាទីបំផុត ប៉ុន្តែសម្ដេចអាចរៀន អាចយល់ច្បាស់លាស់ដោយឆាប់រហ័ស គួរអោយកោតសសើរពន់ពេកណាស់ ។

សម្ដេចទ្រង់ចេះដឹងយល់ធ្លុះធ្លាយចំពោះវេយ្យាករណ៍គ្រប់ភាសា ដែលសម្ដេចបានរៀន មានវេយ្យាករណ៍បាលី សំស្ក្រឹតជាដើម ទាំងអក្សរសាស្ត្ររបស់ជាតិ និងពាក្យពេចន៍ ក្នុងផ្នែកវប្បធម៌បុរាណ ក៏សម្ដេចចេះចាំយល់ហេតុផលជាច្រើនណាស់ ។ ភាសាសៀម ភាសាលាវ និង ភាសាបារាំង ដែលសម្ដេចបានរៀន អាចនិយាយប្រស្រ័យ ទាក់ទងនឹងជនជាតិសៀម

ជាតិលាវ និង ជាតិបារាំងបាន ។ សម្តេចឈ្លាសវៃប្រសប់យក តម្រាប់តាមសំឡេងភាសាជាតិដទៃៗអោយស្រដៀង ឬដូចភាសាជាតិដទៃទៀតបាន ។ ភាសាអង់គ្លេស និង ភាសាវៀតណាម ក៏សម្តេចបានរៀនអាចមើលសរសេរនិយាយប្រស្រ័យបានច្រើនដែរ ។ ក្នុងសម័យដែលសម្តេចកំពុងសិក្សាវិជ្ជាខាងបាលីក្នុងរវាង គ.ស. ១៩១០ ឃើញថា សម្តេចមានព្រះកិត្តិស័ព្ទល្បីថាជាព្រះថេរៈស្ទាត់ជំនាញពូកែខាងភាសាបាលី អាចនិយាយភាសាបាលីបានច្រើនជាងភិក្ខុសាមណេរឯទៀតដែលរៀនជាមួយគ្នាក្នុងសម័យនោះ ។

នៅព.ស.២៤៥៧ គ.ស.១៩១៣ សម្តេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាមវិហារ ព្រះកែវមរកត ចំពោះព្រះភក្ត្រព្រះករុណា ព្រះបាទសម្តេច ព្រះ ស៊ីសុវត្ថិ បាន៤ប្រយោគដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។

ព.ស. ២៤៥៩ គ.ស. ១៩១៥ សម្តេចទ្រង់បានប្រឡងជាប់លេខ ២ ដោយបាន ទទួលការតែងតាំងជាសាស្ត្រាចារ្យ នៅសាលាបាលីជាន់ខ្ពស់ដែលសព្វថ្ងៃមានឈ្មោះថា **ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត** ។

ក្រៅពីភាសាខ្មែរ ដែលសម្តេចទ្រង់បានស្រាវជ្រាវយល់ឫសគល់ពិតប្រាកដ សម្តេចបានសិក្សាភាសាបាលីអាចអាន ឬសន្ធនាតាមសំនៀងជាតិបរទេសបានទាំងអស់ គឺ សំនៀង លង្កា ភូមា មន សៀម និង លាវ ឥតមានទើសទាក់ ភ្លាំងភ្លាត់ឡើយ ។

នៅព.ស. ២៤៦៦ និង ២៤៦៧ និង ១៩២៣ សម្តេចកាលនៅជាព្រះគ្រូសង្ឃសត្ថា (ជាមួយនិងសម្តេចព្រះពោធិវង្ស **ហួត តាត** វជិរប្បញ្ញោ កាលនៅជាព្រះគ្រូសង្ឃវិជ្ជា) បានធ្វើជាសមណនិស្សិត និមន្តទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និងអក្សរសិលាចារឹក ជាដើមនៅសាលាបារាំងសែសចុងបូព៌ាប្រទេសនាក្រុងហាណូយ(វៀតណាមខាងជើង) ក្នុងសំណាក់លោក **ល្វី ហ្វីណូត៍** (ជាតិបារាំងសែស) ជាចាងហ្វាងសាលានេះ "

## ៦- បេសកម្មបរិច្ឆេទ កំណត់អំពីការទទួលបម្រើកិច្ចការ

ព.ស. ២៤៦៣ គ.ស. ១៩១៩ សម្តេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិកាកាន់កិច្ចការផ្ទាល់លុះត្រាបានចប់ចុងចប់ដើម ។

ព.ស. ២៤៦៩ គ.ស. ១៩២៥ សម្តេចបានធ្វើជាសមាជិក នៃក្រុមជំនុំពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ។

ព.ស. ២៤៧០ គ.ស. ១៩២៦ តមកជាច្រើនឆ្នាំ សម្តេចទ្រង់បានទទួលការតែងតាំងនាមប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាខ្មែរ និង ការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ បារាំង-ខ្មែរ នៅក្រុងភ្នំពេញ ។

ព.ស. ២៤៧៤ គ.ស. ១៩២៧ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរ ហើយសម្តេចទ្រង់បាន

ទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់បាន បោះពុម្ពផ្សាយទាំងភាគ១ ភាគ២បាន ៥គ្រាហើយ ។

ក្នុងឆ្នាំនេះ សម្ដេចបានទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្ដាច់ឆ្នាំសម្រាប់បណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃហៅថាវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ។

/ ព.ស. ២៤៧៤ គ.ស. ១៩៣០ សម្ដេចទ្រង់បានទទួលការតែងតាំងក្នុងមុខតំណែងជាចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ។

ក្នុងឆ្នាំដដែលនោះ សម្ដេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសពាក្យពេចន៍ក្នុងផ្ទៃនៃកវីនិពន្ធខ្មែរបុរាណដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ ។

ព.ស. ២៤៧៧ គ.ស. ១៩៣៣ សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។

ព.ស. ២៤៧៨ គ.ស. ១៩៣៤ សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរ ប្រៀបធៀបនឹង ពាក្យបារាំងសំរាប់ប្រើក្នុងការងាររាជការ។

/ ព.ស.២៤៧៩ គ.ស.១៩៣៥ សម្ដេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹតខ្មែរ និង លាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សានៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។ /

# ៧-ឋានន្តរបរិច្ឆេទ កំណត់អំពីឋានន្តរ

ព.ស.២៥៨៦ . គ.ស ១៩៤២ សម្តេចទ្រង់បានទទួលឋានន្តរជាចាងហ្វាង នៃ សាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ដែលសព្វថ្ងៃកែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ព.ស.២៤៨៨ . គ.ស. ១៩៤៤ សម្តេចទ្រង់បានទទួលដំណែងជាចៅអធិការ វត្តឧណ្ណាលោម ។

ព.ស.២៤៨៩ គ.ស១៩៤៥ សម្តេចទ្រង់បានទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ ។

ព.ស.២៤៩១ . គ.ស. ១៩៤៧ សម្តេចទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ "ក" នៃគណៈកម្មការជាតិខាងការសិក្សា ។

ព.ស.២៤៩២ . គ.ស. ១៩៤៨ ទ្រង់បានទទួលនាទីជាគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅ សំរាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ ។

គ.ស.១៩៦១ . រហូតមកសម្តេចទ្រង់ប្រោសមេត្តាទទួលនិមន្តរបស់សមាគមអ្នកនិពន្ធខ្មែរធ្វើជាព្រះប្រធាននៃការសម្ភាសន៍អក្សរសាស្ត្រ ដែលផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃសុក្រ ។

គ.ស.១៩៦៨ . ទ្រង់ទទួលឋានៈជាព្រះប្រធានគណៈកម្មការពិនិត្យអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ ។

គ.ស.១៩៦៩ ព្រះអង្គទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យ និង កំណត់អំពីវិន័យរបស់ទង់ជាតិខ្មែរ ។

## ព្រះកិច្ចការដែលសម្តេចទ្រង់បានបំពេញ
## ក្នុងព្រះពុទ្ធសាសនានៅបរទេស

នៅ ព.ស. ២៤៧៥ . គ.ស.១៩៣១ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូ នៃមន្ត្រីសង្ឃទៅកាន់ក្រុងវៀងចន្ទន៍ និង ក្រុងហ្លួងព្រះបាងប្រទេសលាវ ដើម្បីរួបរួមក្នុងពិធី សម្ពោធពុទ្ធសាសនបណ្ឌិត្យប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សា សម្រាប់សាលាបាលីរងនៅប្រទេសលាវផង ។

នៅ ព.ស. ២៤៧៧ . គ.ស.១៩៣៣ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ ចំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំងស៊ីនកម្ពុជាក្រោម ។

នៅ ព.ស. ២៤៨៣ . គ.ស.១៩៣៩ សម្តេចបានដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំកិច្ចការនៃព្រះពុទ្ធសាសនាបណ្ឌិតប្រទេសលាវ និងការសិក្សាសំរាប់សាលាភាសាបាលីនៅប្រទេសលាវផង ដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវ ឱ្យមានការសិក្សាព្រះបរិយត្តិធម៌ និងការប្រតិបត្តិព្រះពុទ្ធសាសនាឱ្យស្របគ្នាតាមរបៀបការសិក្សា និងការប្រតិបត្តិព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ទាំងប្រជាជាតិ នៅក្នុងទីប្រជុំជន និងក្នុងខេត្តនានា នៃព្រះរាជាណាចក្រលាវ ឱ្យខំប្រឹងយកចិត្តទុក ដាក់ក្នុងការសិក្សា និង ការប្រតិបត្តិឱ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង ។

នៅ ព.ស.២៤៨៤ គ.ស.១៩៤៣ សម្តេចទ្រង់បានទទួលនាទីជាសមាជិកឆ្លើយឆ្លង នៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ហើយនៅ ព.ស.២៤៩២ . គ.ស.១៩៤៨ សម្តេចទ្រង់ទទួលនាទី ជាសមាជិកកិត្តិយសនៃសាលានេះដរាបរៀងមក ។

នៅព.ស.២៤៩៤ . គ.ស.១៩៥០ សម្តេចបានដឹកនាំគណៈប្រតិភូខ្មែរទៅប្រជុំសន្និសិទ ដើម្បីបង្កើតពុទ្ធិកសមាគមពិភពលោក នៅក្រុងកោលម្បូ ប្រទេសស្រីលង្កាទ្វីប ។

នៅ ព.ស.២៤៩៧ . គ.ស.១៩៥៣ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅបំពេញបសកម្មសុឆន្ទៈ ប្រឹក្សា សម្រេចរឿងឆដ្ឋសង្គាយនា នៅក្រុងរង្គូន សហភាពភូមា ។

ក្នុងឆ្នាំបន្ទាប់នៅ ព.ស.២៤៩៨ . គ.ស.១៩៥៤ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរនិមន្តទៅកាន់ក្រុងរង្គូនប្រទេសភូមាម្តងទៀត ដើម្បីរួមការប្រជុំធ្វើ ឆដ្ឋសង្គាយនាសម័យប្រជុំដំបូង ។

ក្នុងមួយឆ្នាំក្រោយមក ព.ស.២៤៩៩ . គ.ស.១៩៥៥ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ទីឆដ្ឋសង្គាយនា ក្រុងរង្គូន ប្រទេសភូមាជាលើកទីបី ដើម្បីប្រជុំ ហើយបិទសម័យប្រជុំប្រចាំឆ្នាំ ។

នៅព.ស.២៥០៣ . គ.ស.១៩៥៩ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ក្រុងជាកាតា និង ក្រុងសីម៉ារាំង កោះជ្វា ប្រទេសឥណ្ឌូណេស៊ី ដើម្បីរួមក្នុង ពិធីបុណ្យវិសាខបូជា ព.ស.២៥០៣ ពិធីបញ្ចុះ

ខណ្ឌសីមា និងពិធីសន្មតរោងឧបោសថ ព្រមទាំងជាព្រះឧបជ្ឈាយ៍ បំបួសកុលបុត្រអ្នកប្រទេសនោះចំនួនបីរូបផង ។

## ៨- សមណសក្តិបរិច្ឆេទ កំណត់អំពីសមណស័ក្តិ

ដោយព្រះមហាវិរិយភាពរបស់សម្តេច ដែលទ្រង់បានបំពេញទាំងផ្លូវព្រះពុទ្ធសាសនា ទាំងផ្លូវលោកដែលយើងបានឃើញជាភស្តុតាង សម្តេចក៏បានឡើងសមណស័ក្តិ ជាលំដាប់លំដោយដូចតទៅនេះគឺ :

ព.ស.២៤៥៤ . គ.ស. ១៩១០ សម្តេចបានទទួលការតែងតាំងសមណស័ក្តិ ជាព្រះបាឡាត់សាក្យបុត្តិយ៍ ( បាឡាត់របស់ ព្រះសាក្យវង្ស **នុត** វត្តឧណ្ណាលោម) ។

ព.ស.២៤៥៦ . គ.ស. ១៩១២ សម្តេចបានទទួសសមណស័ក្តិជាព្រះគ្រូសង្ឃសត្ថា (ទីឋាននុក្រមសម្រាប់ឯក របស់សម្តេច ព្រះសង្ឃរាជ ព្រះនាម **ទៀង**)

ព.ស.២៤៧៥ គ.ស.១៩៣១ សម្តេចបានឡើងសមណស័ក្តិ ជាព្រះសាសនសោភ័ណ(រាជាគណៈកិត្តិយស) ។

ព.ស.២៤៨៤ គ.ស.១៩៤០ សម្តេចបានឡើងសមណស័ក្តិ ជាព្រះពុទ្ធឃោសាចារ្យ (រាជាគណៈថ្នាក់ទី២) ។

ព.ស.២៤៨៨ គ.ស. ១៩៤៤ សម្តេចបានឡើងសមណស័ក្តិជាព្រះពោធិវង្ស (រាជាគណៈថ្នាក់ទី១) ។

ព.ស.២៤៩២ គ.ស. ១៩៤៨ សម្តេចបានឡើងសមណស័ក្តិខ្ពស់បំផុត ជាព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយនៃកម្ពុជា ។

ព.ស.២៤៩៤ គ.ស. ១៩៥០ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់បានប្រោសប្រគេនព្រះឋានៈ ជាសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

លុះដល់មក ព.ស.២៤៩៨ គ.ស. ១៩៥៤ រដ្ឋាភិបាលសហភាពភូមាបានប្រគេន ព្រះឋានៈ សម្តេចជា **ព្រះអគ្គមហាបណ្ឌិត សហភាពភូមា** ។

លុះមកដល់ ព.ស.២៥០១ គ.ស. ១៩៥៧ រដ្ឋាភិបាលសហភាពភូមាបានសូមតម្លើង ព្រះឋានៈសម្តេចជា **ព្រះអភិធជមហារដ្ឋគុរុ នៃសហភាពភូមា** ទៀត ដែលជាសមណៈស័ក្តិ ដ៏ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា ។

ខែកុម្ភៈ គ.ស.១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់បានថ្វាយព្រះឋានៈព្រះអង្គជា **ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ** និងជាសមាជិកកិត្តិយសនៃ**សមាគមអ្នកនិពន្ធខ្មែរ** ផង ។

ព.ស.២៥០៧ គ.ស.១៩៦៣ **សម្តេចព្រះនរោត្តមសីហនុ ព្រះប្រមុខរដ្ឋ** នៃ ប្រទេសកម្ពុជា ទ្រង់បានប្រោសប្រទានព្រះឋានៈ សម្តេចជា **សម្តេចព្រះសង្ឃរាជថ្នាក់ទី១** ។

ថ្ងៃទី ២៨ ឧសភា ១៩៦៧ ទ្រង់បានទទួល សញ្ញាបត្រ "**បណ្ឌិតអក្សរសាស្ត្រ**" ពេញលក្ខណៈ អំពីសម្តេចព្រះប្រមុខរដ្ឋ ក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៃភូមិន្ទសកលវិទ្យាល័យ ។

## ៩- គ្រឿងឥស្សរិយយសបរិច្ឆេទ កំណត់អំពីឥស្សរិយយស

គ្រឿងឥស្សរិយយស ដែលសម្តេចទទួលដូចតទៅនេះគឺ

-**មេដាយអស្សឫទ្ធិមុនីសារាភរណ៍** នៅ ព.ស. ២៤៦១ គ.ស. ១៩១៧ ។

-**មេដាយអស្សឫទ្ធិព្រះរាជាណាចក្រកម្ពុជា** នៅ ព.ស ២៤៧៦ គ.ស១៩៣២ ។

-**មេដាយអស្សឫទ្ធិដំរីមួយលាន និង ស្វេតច្ឆត្រប្រទេសលាវ** នៅ ព.ស. ២៤៧៦ គ.ស. ១៩៣២ ។

-**មេដាយសេនា នៃបណ្ឌិតសភា** សាធារណៈរដ្ឋបារាំង នៅ ព.ស. ២៤៨១ គ.ស.១៩៣៧ ។

-**មេដាយអស្សឫទ្ធិជីឡាឡេស្យុងដូណេ្ណីរ** នៃសាធារណៈរដ្ឋបារាំង នៅ ព.ស. ២៤៨៦ គ.ស. ១៩៣៧ ។

-**មេដាយសេនា នៃព្រះរាជាណាចក្រកម្ពុជា** នៅ ព.ស.២៤៨៨ គ.ស.១៩៤៤។

-**មេដាយសេនាជីឡាឡេស្យុងដូណេ្ណីរ** នៃសាធារណៈរដ្ឋបារាំង នៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ ។

-មេដាយមហាសិរីវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៥០៥ គ.ស. ១៩៦២ ។

-មេដាយមហាសិរីវឌ្ឍន៍សុវត្ថារា នៅ ព.ស. ២៥០៦ គ.ស. ១៩៦៣ ។

-មេដាយជាតូបការ ដែលជាគ្រឿងឥស្សរិយយសធំបំផុតក្នុងព្រះរាជាណាចក្រកម្ពុជា នៅ ព.ស.២៥១៣ គ.ស. ១៩៦៩ ។

## ១០-ពុទ្ធវុឌ្ឍិបរិច្ឆេទ កំណត់អំពីការធ្វើសេចក្តីចម្រើនក្នុងផ្លូវលោក និង ផ្លូវព្រះពុទ្ធសាសនា

កិច្ចការឯទៀតរបស់សម្តេច ក្រៅពីមុខការខាងសិក្សា ដែលសុទ្ធតែជាការមានប្រយោជន៍ជាសាធារណៈក្នុងព្រះពុទ្ធសាសនា និងប្រទេសជាតិនោះ នៅមានច្រើនទៅទៀត និយាយដោយសង្ខេប គឺចាប់តាំងពីឆ្នាំឆ្លូវសប្តស័ក ព.ស២៤៧០ គ.ស១៩២៤ រៀងមក សម្តេចបានធ្វើការឧបត្ថម្ភវត្តពោធិព្រឹក្ស(ហៅវត្តពោល្យាំ)ក្នុងសង្កាត់រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់គ្នានឹងសង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាទីជាតិភូមិរបស់សម្តេច ដូចមាន សេនាសនភណ្ឌ តទៅនេះ ÷

១-សម្តេចបានជាវដីជុំវិញវត្តចំនួនជាពាហិតា ពង្រីកទីវត្តឱ្យធំទូលាយច្រើនជាងពីដើម ។

២-បានជួយឧបត្ថម្ភលើកថ្នល់ភ្ជាប់ពីថ្នល់ជាតិចូលមកវត្ត សុរភី និង ពោធិព្រឹក្ស រួមចម្ងាយ ៣គីឡូម៉ែត ។

៣-បានស្ថាបនាវិហារបេតុងអាម៉េ សាលាបាលីរង(ពុទ្ធិកបឋមសិក្សា) រៀបចំទីវត្តពោធិព្រឹក្សទាំងមូល អោយមានទេសភាពសមរម្យ តាមសម័យនិយម ។

៤-បានស្ថាបនា ស្ពានធំមួយនិងស្ពានតូចមួយ សុទ្ធតែបេតុងអាម៉េឆ្លងស្ទឹងតូច ទាំងព្រំប្រទល់សង្កាត់រលាំងកែន និង សង្កាត់រកាកោះ ។

៥-បានឧបត្ថម្ភក្នុងការស្ថាបនា សាលាបឋមសិក្សាបំពេញវិជ្ជា **សុរភី** ពោធិព្រឹក្ស ៣ខ្នង តាំងពីគ.ស១៩៤៨ រៀងរហូតដល់សាលានេះ ឡើងដល់ថ្នាក់ឧត្តមដ្ឋាន សម្រាប់កូនចៅអ្នកស្រុកជើងវត្ត **សុរភី** និងវត្ត **ពោធិព្រឹក្ស** ។

៦-បានឧបត្ថម្ភអោយគេធ្វើថ្នល់លំមួយចាក់ក្រួសបាយក្រៀមប្រើការបានដោយងាយស្រួល ។

៧-បានជាវទីដី ៣ហិតាកន្លះទុកដាក់ជាសាសនសម្បត្តិតរៀងទៅ ។

៨-បានស្ថាបនា ក្លោងទ្វារបេតុងអាម៉េមួយ ។

៩-បានស្ថាបនា អាវសថសាលា(សាលាជំណាក់) ១ខ្នង ។

១០-បានចាត់ការអោយជីកស្រះមួយទំហំ ១០០ម៉ែត្រ៤ជ្រុង នៅត្រង់ទីថ្នល់បែក ចេញពីថ្នល់ជាតិក្នុងសង្កាត់រកាកោះ ។

១១-បានជួយឧបត្ថម្ភជីកអណ្តូងយោង១៦កន្លែង អណ្តូងបុកប្រើស្នប់៣កន្លែង ។

១២-បានជួយស្ថាបនាគិលានដ្ឋានមួយខ្នង ប្រសូតគ្រឹះ (មន្ទីរសម្ភព) មួយខ្នង ដោយបេតុងអាម៉េ ។

១៣-បានធ្វើកំពែងបេតុងអាម៉េ បណ្តោយ ១០០ម៉ែត្រ ទទឹង ៥២ម៉ែត្រពទ្ធ័ ជុំវិញមន្ទីរពេទ្យទាំងពីរខ្នងនេះ ។

១៤-បានស្ថាបនា អគារគព្ភិនីសំណាក់ក្នុងកំពែងនោះដែរ ។

១៥-បានស្ថាបនាអាគារបេតុងអាម៉េ ២ខ្នងក្រៅកំពែងនោះ សម្រាប់គិលានសមណៈ ។

១៦-បានចាត់ការឱ្យលើកទំនប់ទឹក ១កន្លែង បណ្តោយ ៩០០ម៉ែត្រ ទទឹង ៨០០ម៉ែត្រ(ដោយសម្តេចព្រះ **នរោត្តម សីហនុ** ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហរទ័យប្រោសប្រទានព្រះរាជានុញ្ញាតឱ្យលើកទំនប់ទឹកនេះ) ។

១៧-បានឧបត្ថម្ភឱ្យវេយ្យាវច្ចករដាំដំណាំលើទឹកដីខាងលើនេះ ជាប្រយោជន៍ដល់គិលានដ្ឋាន និងប្រសូតិគ្រឹះ របស់សម្តេចទៅក្នុងអនាគតកាល (ស្ថាបនកម្មទាំងនេះ នៅក្នុងភូមិស្រែបន្ទាយ សង្កាត់រការកោះ) ។

១៨-បានលះបង់ដីមួយកន្លែង ដែលសម្តេចបានជាវហើយនោះ ជូនព្រះរាជរដ្ឋាភិបាលអោយស្ថាបនា អគារមណ្ឌល នីតិកម្ម(ប៉ុស្តិប៉ូលីស) និងមន្ទីររាជសហករណ៍។ល។

១៩-បានផ្តើមគំនិតធ្វើសហគមន៍ កសាងមន្ទីរពេទ្យព្រះសង្ឃ ក្រុងភ្នំពេញ ។

២០-បានកសាងវិហារវត្តឧណ្ណាលោម ដែលជាវិហារធំបំផុត ជាង វិហារទាំងអស់ ក្នុងប្រទេសកម្ពុជា ហើយមានពជាន់ ក្នុង ព.ស២៤៩៩ គ.ស១៩៥៦ ។

២១-បានផ្តើមកសាងព្រះសក្យមុនីចេតិយ នៅខាងកើតស្ថានីយ រាជាយស្ម័យយាន ។

២២-បានទំនុកបម្រុង ព្រមទាំងចាត់ចែងសមណៈនិស្សិត បញ្ជូនឱ្យ ទៅរៀននៅឯបរទេស មានប្រទេសឥណ្ឌា ភូមា ជាដើម ។

២៣-បានបង្កើតការសិក្សាធម្មវិន័យ ដើម្បីសិក្ខាកាមកុលបុត្រទូទៅ ពេញប្រទេសកម្ពុជា ។

២៤-បានបង្កើតការអប់រំយុវជន ដោយសីលធម៌ ដែលនៅក្នុងវត្ត ឧណ្ណាលោម ឬ វត្តឯទៀត ដែលមានយុវជននៅវត្តជាច្រើននាក់ ។

២៥-បានផ្តើមកសាងឈាបនដ្ឋាន(ទីបូជាសព) ក្នុងវត្តឧណ្ណាលោម ដោយមាន លោកអ្នកឧកញ៉ាតេជះ **តាន់ ម៉ៅ** ជាអ្នកចេញប្រាក់កសាង អោយកើតមានក្នុងប្រទេសកម្ពុជាមុនដំបូងបង្អស់ គ.ស ១៩៥៣ ។

២៦-បានផ្តើមសង់ឧបដ្ឋានសាលា សម្រាប់មន្ត្រីសង្ឃដែលនិមន្តមក ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាត ដើម្បីប្រជុំទទួលភត្តាហារនិងសម្រាប់ភ្ជុំបិណ្ឌ ដែលគហបតី **លី ស៊ុនងន** ឧបាសិកា **តាន់ ស៊ីប៊ី** ចេញប្រាក់កសាង ។

២៧-បានបង្កើតអោយមានការហាត់រៀនប្រលងសូត្របាតិមោក្ខបាលី។

២៨-បានរៀបចំតាំងគណៈកម្មការសង្ឃ និងគណៈកម្មការគ្រហស្ថ តាមផ្លូវការគ្រប់វត្តទាំងអស់ដើម្បីរៀបចំទីវត្តឱ្យស្អាត ទាំងមានរបៀបរៀបរយ តាំងពីឆ្នាំ ១៩៥៥ ដរាបមក ។

២៩-បានបង្កើតទង់ព្រះពុទ្ធសាសនា ឱ្យត្រូវស្របគ្នានឹងទង់ព្រះពុទ្ធសាសនា នៃ ប្រទេសឥណ្ឌា លង្កា ជាដើម ។

៣០-បានផ្ដើមពិធីបុណ្យសម្ភោធឆ្លងព្រះត្រៃបិដកក្នុងកាល ព.ស ២៥១២ គ.ស ១៩៦៩ ឋិតនៅក្រោមព្រះរាជធិបតី ភាពនៃព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ។ ពិធីសម្ភោធព្រះត្រៃបិដករាប់ថាជាមូលហេតុធំមួយតាមផ្លូវការ របស់រាជរដ្ឋាភិបាល នាំឱ្យពុទ្ធសាសនបណ្ឌិត្យជាវព្រះត្រៃបិដកប្រគេនជូន ចំពោះព្រះសង្ឃ និងគ្រហស្ថ បានប្រាក់ថវិកា ជាតិជាងដប់លានរៀល (១០.០០០.០០០) ។

៣១-បាននាំយកកូន និងផ្លែសាលព្រឹក្ស ពីប្រទេសឥណ្ឌាមកចែកផ្សាយឱ្យប្រទេសយើងដាំបានច្រើនវត្ត មាន វត្តឧណ្ណាលោម និង វត្តនិរោធរង្សីជាដើម ។

៣២-បានជួយកសាងវត្តជាច្រើន គឺវត្តមុន្នីរង្សី(ហៅឃ្លាំងខ្នុត)ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ វត្តជោតញ្ញាណ ក្រុងព្រះសីហនុកំពង់សោម វត្តជោតញ្ញាណក្នុង ខេត្តកោះកុង បានផ្ដើមកសាងវត្តជោតនារាម ហៅបឹងកុក នៅក្នុងទីក្រុងខេត្តកំពង់ចាម វត្តនារាយណ៍ ក្នុងស្រុកឈូក

ខេត្តកំពត និងវិហារមួយខ្នង នៅក្នុងបរិវេណមន្ទីរពេទ្យព្រះសង្ឃ ដោយមានគហបតី **តាន់ ហុងអាន** ជាអ្នកបរិច្ចាគប្រាក់កសាង ។

## ស្នាព្រះហស្តខាងអក្សរសាស្ត្រនៃសម្តេច

**សម្តេចព្រះសង្ឃរាជ** បានកសាងគម្ពីរដីកាជាច្រើនណាស់ ទាំងគម្ពីស្លឹករឹត ទាំងសៀវភៅ ជាពិសេសគឺសៀវភៅដែលសម្តេចប្រមូលរៀបរៀង និងសៀវភៅដែលទ្រង់ប្រែបាលីមកជាភាសាខ្មែរសម្រាប់ពុទ្ធបរិស័ទរៀនសូត្រ ។ សៀវភៅខ្លះ ជាសៀវភៅ ដែលកម្រនឹងធ្វើកើត ទាំងមានប្រយោជន៍ជាច្រើនណាស់ គឺ :

១-**វចនានុក្រមខ្មែរ** មាន ២ភាគ ក្នុង ព.ស២៤៦១ , គ.ស១៩១៧ សៀវភៅនេះបានបោះពុម្ពច្រើនគ្រាមកហើយ ។

២-**កច្ចាយនរូបត្ថម្ភកៈ** (វេយ្យាករណ៍បាលី) មាន ២ភាគ តាំងពី ព.ស២៤៦២ គ.ស១៩១៨ បានបោះពុម្ពច្រើនគ្រាមកហើយ ។

៣-**គហិបដិបត្តិ** ក្នុង ព.ស២៤៦៨ គ.ស១៩២៦ ជាមួយនឹងព្រះឧត្តមមុន្នី **អ៊ុម ស៊ូ** និងព្រះពោធិវង្ស **ហួត តាត** តាមបញ្ជានៃព្រះតេជព្រះគុណព្រះមហាវិមលធម្ម **ថោង** (ពុទ្ធសាសនបណ្ឌិត្យ) ។

៤-**សាមណេរវិន័យ** ក្នុង ព.ស២៤៦០ គ.ស១៩១៧ ជាមួយព្រះថេរៈទាំងពីរព្រះអង្គខាងលើនេះដែរ ។

៥-**បាដិមោក្ខសំវរសង្ខេប** (សម្រាយ) ព.ស២៤៧០ គ.ស១៩២៨ បានបោះពុម្ពច្រើនគ្រាមកហើយ ។

មានសៀវភៅឯទៀតៗ ជាច្រើនទៀតដែលជាបន្ទាប់បន្សំគឺ

៦-**កាព្យលោកធម៌**បោះពុម្ពដំបូងក្នុង ព.ស ២៥០០ គ.ស ១៩៥៧។ កាព្យនេះទ្រង់តែងកាលនៅជាព្រះគ្រូសង្ឃសត្ថា ។

៧-**នាគោបមាទិកថា** ព.ស ២៤៧៥ គ.ស ១៩៣៣ ។

៨-ព.ស ២៤៨៤ គ.ស ១៩៤១ សម្ដេចបានតែង **សុភមង្គលគាថាបាលីបថ្យាវត្ត ៧គាថា** ព្រមទាំងប្រែសម្រាយផង សម្រាប់សូត្រថ្វាយសុភមង្គលសួស្ដីចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុវរ្ម័ន** ។

៩-**បញ្ញាខន្ធកៈសង្ខេប** ។

១០-**ចីវរក្ខន្ធកៈពិស្ដារ** ។

១១-អត្ថបទផ្សេងៗជាច្រើនក្នុងទស្សនាវដ្ដីកម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ តាំងពីឆ្នាំ១៩២៦ និងឆ្នាំតៗមក ដែលពុំអាចស្រាវជ្រាវមកដាក់ក្នុងទីនេះបានដោយពេលមមាញឹក ព្រមទាំងអត្ថបទធម៌ឯទៀតៗជាច្រើនដែលបោះពុម្ពចុះក្នុង ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ ។

១២-បានពិនិត្យកែសម្រួលពាក្យពេចន៍ របស់គណៈកម្មការខេមរយានកម្ម ដោយព្រះមេត្តាជួយឱ្យគណៈកម្មការ នេះជារបស់ក្រសួងអប់រំជាតិ បានរួបរួមបោះពុម្ពសៀវភៅទស្សនាវដ្ដីសម្រាប់បង្រៀនសិស្សផ្នែកមធ្យមសិក្សាចេញរៀងរាល់ខែ ។

ព្រះកេរ្តិ៍មួយសំខាន់ណាស់ ដែលរំលឹកឃើញរាល់ថ្ងៃ គឺព្រះរាជនិពន្ធទំនុកច្រៀង **បទនគររាជ** សម្រាប់ភ្លេងជាតិខ្មែរ ទ្រង់បាននិពន្ធពីថ្ងៃទី ២០-០៧-១៩៤១ និងទំនុក ព្រមទាំង **បទសរភញ្ញ** ដែលទ្រង់បាននិពន្ធកាលពីឱកាសបុណ្យពុទ្ធ សករាជ ២៥០០ ។

## ព្រះគុណសម្បត្តិនៃសម្តេចព្រះសង្ឃរាជ

គុណសម្បត្តិនៃសម្តេចជាអម្ចាស់ មានច្រើនយ៉ាងណាស់ ប៉ុន្តែយើងខ្ញុំបានពិចារណាដោយហ្មត់ចត់ ហើយសរសេររួបរួមប្រមូលយកចំពោះតែគោលធំៗ ដោយសង្ខេបមាន ៥យ៉ាង ដូចសេចក្តីរៀបរៀង វែកញែកតទៅនេះ

**១-វិរិយភាពក្នុងការសិក្សា**

**២-បដិភាណប្បញ្ញា (ប្រាជ្ញាវាងវៃ)**

**៣-វេសារជ្ជប្បញ្ញា (បញ្ញាក្លៀវក្លាអង់អាច)**

**៤-ធម្មទេសនាកោសល្យ (ភាពឈ្លាសវៃក្នុងធម្មទេសនា)**

**៥-បណ្ឌិតសកម្មភាព (សកម្មភាពដ៏ប្រសើរ) ។**

## អធិប្បាយពង្រីកសេចក្តីចំពោះគុណសម្បត្តិមួយៗ

## ១-វិរិយភាព

វិរិយភាព នៃសម្តេចជាអម្ចាស់ ដែលមនុស្សចាស់ទុំធ្លាប់បានសង្កេតតាំងអំពីសម្តេចមានព្រះជន្មនៅក្មេង គឺតាំងពីនៅជាសាមណេរដរាបមករហូតដល់សម្តេចមានព្រះជន្មជ្រុលចូលមកដល់បច្ឆិមវ័យហើយ ក៏នៅតែមានព្យាយាម

ឥតមានបន្ធូរបន្ថយ បញ្ឈប់សេចក្តី ព្យាយាមនោះឡើយ សូម្បីព្រះអង្គមានសមណស័ក្តិដ៏ខ្ពង់ខ្ពស់បំផុតទីជាសម្តេចព្រះសង្ឃរាជហើយក៏ដោយ ។

**វិរិយភាពនេះ** ប្រែថា សេចក្តីព្យាយាមឬថាប្រឹងប្រែង រាប់ថាជាបារមីមួយរបស់ព្រះពោធិសត្វដែលយើងធ្លាប់ចេះដឹងមកហើយ ហៅថា **វិរិយបារមី** ។ បណ្តាកិច្ចការគ្រប់យ៉ាង រមែងប្រកមដោយឧបស័គ្គគឺធម៌ជាគ្រឿងរាំង បើមិនច្រើនក៏តិច តែថាបើសេចក្តីព្យាយាមមានកម្លាំងក្លៀវក្លា ក៏អាចពុះពារចំពោះឧបស័គ្គនោះបានដោយពិត ។ **សម្តេចព្រះសង្ឃរាជ** ទ្រង់មានវិរិយធម៌ដ៏រឹងប៉ឹងជាទីបំផុត បានជាព្រះអង្គចេះតែមានជ័យជំនះសង្កត់ទៅលើឧបស័គ្គគ្រប់យ៉ាងបានជាដរាប ទោះបីព្រះអង្គហត់នឿយណាស់ ប៉ុន្តែព្រះអង្គមិនសូវចេះត្អូញត្អែរឡើយ ។

ករណីកិច្ចណាមួយ ដែលគេត្រូវធ្វើដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តីអាចសម្រេចទៅបាន ដោយកម្លាំងនៃសេចក្តីព្យាយាមទាំងអស់ ។ ឥរិយាបទទាំង៤គឺ ការដើរ ឈរ អង្គុយ ដេក ដែលនាំអោយសម្រេចប្រយោជន៍ទៅបាន ក៏ដោយគុណានុភាព នៃសេចក្តីព្យាយាមដែរ ។

**សម្តេចព្រះសង្ឃរាជ** ព្រះអង្គមានវិរិយបារមីដ៏បរិបូណ៌ណាស់ សូម្បីសម្តេចដែលមានព្រះជន្ម ៨៦ឆ្នាំហើយ ក៏នៅបំពេញកិច្ចការរបស់ព្រះអង្គឥតមានបន្ធូរបន្ថយព្រះកាយពលឡើយ ។ ដូចយ៉ាងព្រះអង្គចាប់ធ្វើវចនានុក្រមខ្មែរ ទ្រង់ឥតមានសំចៃកម្លាំង និងពេលវេលាទេ ។ សម្តេចយកពេលយប់ធ្វើជាពេលថ្ងៃ យកថ្ងៃធ្វើជាយប់ ខំប្រឹង សរសេររៀបរៀងតាំងពីពេល

ព្រលប់រហូតទល់ភ្លឺក៏មាន លុះទ្រង់សោយយាគូរួចចាប់សរសេរ តទៅទៀតទាល់តែដល់ពេលម៉ោង ១១ក៏មាន ។ ក្នុងរយៈពេលវេលាយប់មួយថ្ងៃមួយសម្តេចទ្រង់ផ្ទំបានតែរវាង ៤ឬ៥ ម៉ោងប៉ុណ្ណោះ ។ ការប្រព្រឹត្តដោយសេចក្តីព្យាយាមនៃសម្តេចព្រះសង្ឃរាជនេះ ជាការកម្រមនុស្សធ្វើបាន ។

## ២-បដិភាណបញ្ញា (ប្រាជ្ញារាងវៃ)

ប្រាជ្ញាសំដៅយកការចេះដឹងយល់ទូទៅ ឬការយល់ច្បាស់លាស់ចំពោះហេតុការណ៍ផ្សេងៗតាមធម្មតា ។ ដែលលោក ហៅថា"**បដិភាណបញ្ញា**" នោះ សំដៅយកប្រាជ្ញាដែលកើតឡើងភ្លាមៗ ហើយអាចឆ្លើយតបវិញបានភ្លាមមិនបាច់គិតគូរអស់វេលាយូរទេ។ ប្រាជ្ញារបស់សម្តេចកើតឡើងរហ័ស ក្នុងពេលដែលគេចោទសួរ ឬ និយាយអោយឮភ្លាមក៏អាចដឹងទាន់ចាប់ភ្លឹក នឹកឃើញឆ្លើយបានវិញភ្លាម ហាក់ដូចជាមានគូសដៅទុកយូរហើយ ។

ប្រាជ្ញាស្មារតីរហ័សរាងវៃប្រកបដោយសមត្ថភាព ឆាប់យល់ហេតុការណ៍គ្រប់យ៉ាង ដែលអាចដឹងទាន់ភ្លាមៗដូចអធិប្បាយដោយសង្ខេបមកនេះហៅថា"**បដិភាណបញ្ញា**"។

**សម្តេចព្រះសង្ឃរាជ** មានបដិភាណបញ្ញានេះបរិបូណ៌ណាស់ ដូចយ៉ាងសម្តេចដែលបានទ្រង់យាងទៅកាន់ទីប្រជុំណាមួយ ដែលមានសមាជិកជាន់ខ្ពស់ហើយគេត្រូវសាកសួរនិយាយពិភាក្សាការណ៍ជាចាំបាច់ ដែលទាក់ទងមកលើសម្តេចភ្លាម ទ្រង់ក៏អាចឆ្លើយដោះស្រាយទាន់ភ្លាមវិញដែរ ។

## ៣-វេសារជ្ជប្បញ្ញា (បញ្ញាអង់អាច ឬ ក្លៀវក្លា)

ភាពនៃប្រាជ្ញាអង់អាចក្លៀវក្លានេះ ជាគុណសម្បត្តិមួយដ៏ប្រសើររបស់មនុស្ស ។ ប្រាជ្ញារបស់សម្តេចព្រះសង្ឃរាជជាអម្ចាស់របស់យើង រាប់ថាជាប្រាជ្ញាមួយដ៏ខ្ពង់ខ្ពស់អាចពោលបានថា សម្តេចមានវេសារជ្ជប្បញ្ញាគ្រប់គ្រាន់ ព្រោះព្រះអង្គបានទទួលព្រះកិត្តិនាម ដ៏ល្បីខ្ចរខ្ចាយទៅក្នុងប្រទេស និងក្រៅប្រទេស ។ ដូចយ៉ាងសម្តេចទ្រង់យាងទៅកាន់ទីប្រជុំធំៗ ក្នុងប្រទេសដទៃ ព្រះអង្គតែងចន្លីសីហនាទ ប្រកបដោយប្រាជ្ញាដ៏ក្លៀវក្លាអង់អាចឥតញាប់ញ័រតក់ស្លុតចំពោះទីប្រជុំនោះឡើយ ។

ប្រាជ្ញាដែលក្លៀវក្លាអង់អាច ដូចអធិប្បាយដោយសង្ខេបមកនេះ ហៅថា **"វេសារជ្ជប្បញ្ញា"** ។

## ៤-ធម្មទេសនាកោសល្យ (ការឈ្លាសវៃក្នុងធម្មទេសនា)

ភាពនៃការឈ្លាសវៃមានច្រើនយ៉ាងគឺ ឈ្លាសវៃក្នុងអំពើបាបក៏មាន ក្នុងអំពើបុណ្យក៏មានឈ្លាសវៃក្នុងអំពើឥតប្រយោជន៍ក៏មាន ក្នុងអំពើមានប្រយោជន៍ក៏មាន ។ ការឈ្លាសវៃក្នុងទីនេះសំដៅយកហេតុការណ៍ដែលមានប្រយោជន៍ចំពោះមនុស្សក្នុងបច្ចុប្បន្ន និងក្នុងអនាគត ។ ដែលហៅថា **"ធម្មទេសនាកោសល្យ"** សំដៅយកការឈ្លាសវៃក្នុងធម្មទេសនា ។ សម្តេចព្រះសង្ឃរាជ ទ្រង់មានភាពឈ្លាសវៃ ក្នុងធម្មទេសនាដោយគ្រប់គ្រាន់ ។

ធម្មទេសនានៃសម្តេច ប្រកបដោយប្រយោជន៍ទាំងផ្លូវលោក ទាំងផ្លូវធម៌ អាចបំភ្លឺពុទ្ធបរិស័ទប្រជាពលរដ្ឋឱ្យយល់ ផ្លូវខុស ផ្លូវត្រូវ អោយជឿ

ជាក់ចំពោះជាតិសាសនា និងព្រះរាជបល្ល័ង្គ ។ ព្រះធម្មទេសនា នៃសម្តេចព្រះសង្ឃរាជ ទុកថាជាមូលដ្ឋានមួយដ៏ស្តុកស្តម្ភ អាចបំភ្លឺប្រជាពលរដ្ឋអោយមានព្យាយាម មានជំហររឹងប៉ឹង អោយប្រឹងប្រែង ប្រកបការងារកុំឱ្យខ្ជិលច្រអូស ឱ្យមានសីលធម៌សាមគ្គីមូលមិត្រជាឯកភាពក្នុង រវាងជាតិសាសនា និង ព្រះរាជបល្ល័ង្គរបស់យើងដើម្បីឱ្យខ្ពង់ខ្ពស់ថ្កើងរុងរឿងទៅអនាគត ។ ធម្មទេសនានៃសម្តេចឈ្មោះថាជាធម្មទេសនា ទោលបំភ្លឺពុទ្ធបរិស័ទ ប្រជាពលរដ្ឋឱ្យយល់ប្រយោជន៍គ្រប់យ៉ាងបំភ្លឺទាំងខាងគុណសម្បត្តិ ទាំងគុណវិបត្តិ ជាធម្មទេសនាប្រកបដោយមធ្យោបាយដ៏ប្រសើរវិសេស អាចដឹកនាំចង្អុលបង្ហាញប្រយោជន៍បច្ចុប្បន្ន និងប្រកបដោយអនាគត ហៅថាជាព្រះធម្មទេសនាដាស់ពុទ្ធបរិស័ទឱ្យភ្ញាក់ខ្លួនក្រោកឡើងប្រកបការងារ ដើម្បីឱ្យមានជីវភាពខ្ពង់ខ្ពស់ឱ្យសមគួរដល់កិត្តិយសរបស់យើងរាល់គ្នាជាប្រជាពលរដ្ឋ របស់ប្រទេសឯករាជ្យ ឱ្យចេះឈឺឆ្អាលស្រឡាញ់ជាតិ សាសនា និង ព្រះរាជបល្ល័ង្គរបស់យើង ។

**សម្តេចព្រះសង្ឃរាជ** មានធម្មទេសនាកោសល្យដ៏បរិបូណ៌។ធម្មទេសនារបស់សម្តេចគួររាប់ថាជាធម្មទេសនាយឹតយោងស្រោចស្រង់ប្រជាពលរដ្ឋឱ្យមានសតិសម្បជញ្ញៈរឹងប៉ឹងបរិបូរណ៌ឡើង ទាំងផ្លូវពុទ្ធចក្រ និង ផ្លូវអាណាចក្រ ដើម្បីឱ្យចក្រទាំងពីរវិលលឿនទៅស្មើៗគ្នា ។ ធម្មទេសនារបស់សម្តេច គួរលើកថាជាធម្មទេសនាបើកលោក គឺប្រទេសកម្ពុជាទាំងមូលឱ្យមានប្រាជ្ញាស្មារតីភ្លឺស្វាងរុងរឿងឡើងដោយពិត ដែលអាចផ្តល់មធ្យោបាយដ៏ប្រសើរឱ្យប្រជាពលរដ្ឋភ្ញាក់ខ្លួនប្រាណចេះជួយខ្លួន ដោយខ្លួនឯង ។

**សម្តេចព្រះសង្ឃរាជ** ជាព្រះធម្មថិកមួយព្រះអង្គយ៉ាងឯក ពុំមានព្រះធម្មថិកអង្គណាមួយប្រៀបស្មើរបានឡើយ ។ ធម្មទេសនាដែលពិរោះ ក្បោះក្បាយ ប្រដាប់ដោយពាក្យពេចន៍ ប្រយោគប្រធាន មានរបៀបរៀបរយ មានកម្រងនៃពាក្យសម្ដីដ៏ត្រឹមត្រូវឥតឃ្លៀងឃ្លាតភ្លាំងភ្លាត់ ទាំងប្រកបដោយឧត្តមគតិ ដៅចំពោះប្រយោជន៍ក្នុងបច្ចុប្បន្ន និង អនាគត ដូចសេចក្ដីអធិប្បាយមកនេះ ហៅថា "**ធម្មទេសនាកោសល្យ**" ។

## ៥-បណីតសកម្ម (សកម្មភាពដ៏ប្រសើរ)

ការងាររបស់សម្ដេចព្រះសង្ឃរាជ សុទ្ធតែជាការងារមានប្រយោជន៍ដ៏ឧត្តុង្គឧត្តមចំពោះពុទ្ធបរិស័ទ ពុំមានការងារណាមួយ ដែលឥតប្រយោជន៍នោះទេ ។

សម្ដេចបានធ្វើបុណ្យផ្សេងៗជាច្រើនដងណាស់ មានកឋិនទានជាដើម ក្នុងឆ្នាំនីមួយៗ បានធ្វើកឋិន ២ឬ៣វត្ត រៀងរាល់ឆ្នាំឥតដែលខានឡើយ ។ កិច្ចការរបស់សម្ដេច សុទ្ធតែមានគោលដៅឆ្ពោះទៅរកសេចក្ដីសុខ សេចក្ដីចម្រើនទាំងលោកខាងមុខដោយពិតប្រាកដ សឹងមានភស្ដុតាងយ៉ាងជាក់លាក់ក្នុងព្រះរាជជីវប្រវត្តនេះ ចូរមើលបរិច្ឆេទនេះ ចូរមើលបរិច្ឆេទនៃព្រះរាជជីវប្រវត្តិត្រង់បរិច្ឆេទទី ៥ ទី៦ និងទី១០ ។

សម្ដេចមានព្រហ្មវិហារដ៏ទូលាយ សង្គ្រោះដល់សាធារណៈជនមិនត្បិតត្បៀតពេកឡើយ ។ កិច្ចការដែលចេះតែមានចេះតែដើរទៅស្រួលមិនចេះ

ឈប់មិនចេះតាំងនៅ ថែមទាំងមានប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ហៅថា "**បណីតសកម្មភាព**" ។

សកម្មភាពរបស់សម្តេចព្រះសង្ឃរាជ, ប្រកបដោយហេតុផលល្អណាស់ អាចបង្ហាញជាឧទាហរណ៍មួយ ដើម្បីបញ្ជាក់ចំពោះវរជនបញ្ញវន្តទាំងសម័យចាស់ សម័យថ្មីដែលគួរជាទិដ្ឋានគតិ (ការយកតម្រាប់តាម) បានដោយពិត ដោយហេតុដែលឃើញរូបរាងកិច្ចការជាភស្តុតាងផង ទ្រឹស្តីក្នុងការងារដ៏ប្រសើរយ៉ាងនេះផង ទើបហៅថា "**បណីតសកម្មភាព**" ។

## ១១-ចរិតលក្ខណបរិច្ឆេទ កំណត់អំពីលក្ខណៈនៃចរិតប្រក្រតី

ការប្រព្រឹត្តជាប់ ដោយកាយវាចារចិត្តគ្រប់ពេលវេលាយូរៗទៅអាចជាប់ទៅជាទំលាប់ ហៅថា"**ចរិតប្រក្រតី**" ។ ដូចយ៉ាងសម្តីគ្រោតគ្រាតដែលធ្លាប់និយាយជាប់ជា ទំនៀប នេះហៅថា ចរិតគ្រោតគ្រាត ។

ការនិយាយកុហកលេងចំពោះមិត្រសំលាញ់យូរៗទៅ ក៏អាចធ្លាប់ជាប់មាត់ជាទំនៀម នេះហៅ ចរិតកុហក ។

ការជក់បារីដើមដំបូងឃើញគេជក់ ក៏ជក់លេងតាមគេយូរៗទៅ ក៏អាចជាប់ជាទំនៀមជក់បារី ។

ការដេកថ្ងៃ ដើមដំបូងឃើញគេដេកថ្ងៃ ក៏ដេកតាមគេ លុះដេកថ្ងៃយូរៗទៅក៏អាចក្លាយជាប់ជាទំនៀម នេះហៅថា ចរិតដេកថ្ងៃ ។

ការប្រព្រឹត្តទាល់តែជាប់ប្រយោគ ដែលអាចលះចេញបាន ដោយកម្រដូច្នេះ ហៅ "**ចរិតប្រក្រតី**" ។

**សម្តេចព្រះសង្ឃរាជ** ព្រះអង្គក៏មានចរិតប្រក្រតីដែរ ប៉ុន្តែចរិតរបស់សម្តេចជាចរិតធូរស្រាល ពុំមែននាំអោយខូចខាតពេលវេលាខូចខាតប្រយោជន៍នោះឡើយ ។

មនុស្សខ្លះ មានចរិតប្រក្រតី ជាប់ជោគធ្ងន់ណាស់ ដូចយ៉ាងចរិតប្រក្រតីផឹកស្រាទាល់តែកឹកជាប់ ដែលអាចលះបង់ ចេញមិនបាន ។ ចរិតប្រក្រតីបែបនេះ ឈ្មោះថាជាចរិត នាំអោយខូចខាត ទាំងជីវិតខ្លួនឯងទាំងទ្រព្យសម្បត្តិរបស់ខ្លួន ។

ការជក់អាភៀន ក៏អាចអោយជាញៀន លះចេញបានដោយកម្រណាស់ ។ ការញៀនអាភៀននេះ ហៅថា ចរិតប្រក្រតីជក់អាភៀន ។មនុស្សអ្នកមានចរិតបែបនេះនាំឱ្យខូចខាតទាំងជីវិត ទាំងទ្រព្យសម្បត្តិជាងចរិតអ្នកផឹកសុរាច្រើនណាស់ទៅទៀត ។

## ចរិតប្រក្រតីនៃសម្តេចព្រះសង្ឃរាជ

១-សម្តេចសោយស្លាម្លូ ជាញឹកញយណាស់ ក្នុងថ្ងៃនីមួយៗ មិនសោយបារីទេ ។ ប៉ុន្តែលោកអ្នកធ្លាប់ដឹងឃើញ និយាយថា សម្តេចព្រះសង្ឃរាជ កាលពីព្រះជន្មវាង ២០វស្សា រហូតដល់ព្រះជន្ម ៣០វស្សា ឃើញសម្តេចសោយបារីដែរ ប៉ុន្តែសោយរម្លើលៗ មិនញឹកញយទេ លុះដល់មកព្រះជន្មវាង ៤០វស្សា ទើបសម្តេចសោយស្លាម្លូ កាន់តែញឹកញយឡើងដរាបមក ។

២-សម្តេច កាលបើមានរោគផ្តាសាយ ដែលនាំអោយតឹងច្រមុះ និងក្អកដោយរោគផ្តាសាយនោះច្រើនតែឃើញ សម្តេចសោយថ្នាំចិន ញាត់ខ្សៀ ហើយសម្តេចមានបន្ទូល ថារោគផ្តាសាយនេះបានតែដកថ្នាំចិនទើបឆាប់ជាសះស្បើយ ថ្នាំចិននេះនាំអោយជា ឬសដូងច្រមុះថែមទៀត ។

៣-សម្តេចមានចរិតប្រក្រតី ក្នុងការសោយក្រយាហារ ច្រើនតែសព្វព្រះទ័យសម្ល ស្រឡក់ ប្រហើរ និងកកូរ ពុំសូវសោយសាច់ឈាមទេ ។ ម្ហូបពាមុខខាងនេះច្រើនតែ អោយគេស្លនឹងត្រីឆ្អើរ បើពុំមានម្ហូបនេះទេច្រើនសព្វព្រះទ័យ ម្ហូបគ្រៀមក្រោះ មានបុកត្រីឆ្អើរ ម្ជូរក្រសាំង ឬផ្លែម្កាក់ជាដើម ។ សម្តេច ពុំសូវសោយបង្អែមច្រើនទេ សោយតែបន្តិចបន្តួច មិនសូវសោយកាហ្វេ ទឹកក្រូច ទឹកម៉ាណាត់ញឹកញាប់ទេ សោយតែទឹកតែ និងស្ករ-ស ។

៤-សម្តេចសព្វព្រះហឫទ័យ នឹងកូនឈើផ្សេងៗដែលមានមែកច្រើន ដូចយ៉ាង ដើមច្រកែងទួយ រទាំងជាដើម យក មកដាំដាក់ក្នុងផើងជាច្រើនចំនួនជាង ១០០ផើង។

៥-ដើមឈើឯទៀតៗ ជាឈើដំណាំស្រុកក្តី ឈើក្នុងព្រៃក្តី សម្តេចសព្វព្រះហឫទ័យដាំច្រើនណាស់ ដូចឈើក្នុងរបងឈាបនដ្ឋានវត្តឧណ្ណាលោម និងឈើឯវត្តពោធិព្រឹក្ស ។

## កម្មវិធីប្រចាំថ្ងៃរបស់សម្តេច

កម្មវិធីរបស់សម្តេចទៀងទាត់ចំពោះត្រង់តែសោយក្រយាហារពេលថ្ងៃត្រង់ហើយនិងពេលដែលធ្វើការ ដូចយ៉ាង សម្តេចសរសេរដកស្រង់ធម៌អាថ៌

រៀបចំសៀវភៅផ្សេងៗ មានវចនានុក្រមខ្មែរជាដើម នេះទៀងទាត់រាល់យប់ ទាល់ៗតែភ្លឺ រវាងម៉ោង៦កន្លះ ឬ ម៉ោង៧ ទើបសោយយាគូ ជូនកាលពេលព្រឹកមិនទាំងសោយយាគូថែមទៀត ឃើញថាពេលយាគូ ពុំសូវទៀងទាត់ទេ។

ពេលដែលសម្តេចកំពុងជាប់ព្រះហស្តសរសេរ ហើយមានភ្ញៀវចូលមកថ្វាយបង្គំគាល់សម្តេចក៏បែរមកធ្វើបដិសណ្ឋារៈភ្លាមៗ ហើយមិនឱ្យនៅយូរទេ ព្រោះមានកិច្ចការច្រើនណាស់ បើថ្ងៃណាមួយដែលសម្តេចទំនេរមិនមានកិច្ចការ ហើយមានភ្ញៀវបព្វជិតឬគ្រហស្ថ ចូលមកថ្វាយបង្គំគាល់នោះ សម្តេចសព្វព្រះរាជហឫទ័យប្រស្រ័យទាក់ទង ដោយព្រះរាជឱង្ការសាកសួរពីនេះពីនោះ ហើយទ្រង់ដឹកនាំបំភ្លឺអំពីផ្លូវលោក ផ្លូវសាសនា យ៉ាងពិស្តារវែងឆ្ងាយណាស់ អស់៤-៥ម៉ោងក៏មាន ទាល់តែភ្លឺក៏មាន មិនចេះត្អូញថា **ងងុយសិង** ថា **ចុករូយស្រពន់ទេ** អោយតែភ្ញៀវនោះទ្រាំអង្គុយចូលចិត្តស្តាប់ចុះ ។ ការណ៍នេះ ចំពោះតែពេលណាមួយដែលសម្តេចមានព្រះសុខភាពរាងកាយស្រួលល្អ ។

ក្នុងថ្ងៃ-យប់នីមួយៗ សម្តេចព្រះសង្ឃរាជចេះតែមានកម្មវិធីជានិច្ចកាល ដូចយ៉ាងកាលសម្តេចនៅក្នុងរវាងព្រះជន្ម ៣០វស្សា រហូតដល់មកព្រះជន្មជាង ៦០វស្សា ក៏នៅខិតខំប្រឹងបង្រៀន ភិក្ខុសាមណេរ ចំនួន ២០ ឬ ៣០អង្គក្នុងពេលយប់ៗ ចំពោះភិក្ខុសាមណេរនៅក្នុងកុដិរបស់ព្រះអង្គខ្លួនមកពីកុដិដទៃខ្លះ ។ សម្តេចមាន កម្មវិធីចំពោះពេលបង្រៀននោះទៀងទាត់ណាស់ ។ កម្មវិធីដែលត្រូវបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ ដែលឥឡូវនេះ

ហៅថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតផង កម្មវិធីបង្រៀនក្នុងពេលយប់ឯកុដិនោះផង ។

# អព្ភូតហេតុ

## មុនពេលដែលសម្តេចព្រះសង្ឃរាជព្រះអាពាធ

នៅថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ត្រូវនឹងថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៦៩ **សម្តេចព្រះសង្ឃរាជ** មានព្រះឱង្ការថា "ខ្ញុំពីយប់មិញឃើញសុបិន្តនិមិត្តមួយចម្លែកណាស់ គឺឃើញចេតិយពីរអណ្តែតលើអាកាសមកអំពីទិសពាយ័ព្យសានតម្រង់មករកខ្ញុំដែលកំពុងអង្គុយនៅយកុដិខាងមុខ ចេតិយនោះមានពណ៌ដូចមាស លុះអណ្តែតចូលមកជិត ឃើញចេតិយនោះកាន់តែតូចហើយបាត់មួយនៅតែមួយ អណ្តែតមកជិតខ្ញុំ ខ្ញុំក៏លូកដៃទៅទ្រចេតិយនោះ រួចក៏ភ្ញាក់ខ្លួនព្រើតឡើងក្នុងពេលជិតភ្លឺ រវាងម៉ោង៤ ។

ព្រះឱង្ការសម្តេចព្រះសង្ឃរាជនេះ ក្នុងពេលប្រជុំសង្ឃដើម្បីតាំងគណៈកម្មការធម្មវិន័យក្នុងថ្ងៃ ២កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ១៩៦៩ ។ បន្ទាប់មកទៀតសម្តេចបានព្រះឱង្ការថា អង្គការធម្មវិន័យរបស់យើងនៅខ្វះសៀវភៅធម៌ជាច្រើនមុខ ព្រោះហេតុនោះ យើងត្រូវតាំងគណៈកម្មការជាថ្មីទៀត ដើម្បីប្រជុំគ្នារៀបចំធ្វើសៀវភៅធម៌ ត្រូវដកស្រង់ធម៌វិន័យអំពីបាលីនិងអដ្ឋកថាមករៀបរៀងអធិប្បាយតម្រូវការតាមថ្នាក់ ត្រី ទោ ឯក។

ត្រង់ពេលដែលខ្ញុំយល់សប្តិឃើញចេតិយនោះ ប្រហែលជានិមិត្តមួយផ្តល់អោយយើងដឹងថា គណៈកម្មការធម្មវិន័យរបស់យើងនឹងបានសម្រេច

ដោយល្អ ។ ព្រះសុបិន្តនិមិត្តនៃសម្តេច ដែលឃើញចេតិយមួយគូនេះទុកជាអព្ភូតហេតុមួយដ៏អស្ចារ្យចម្លែកណាស់។

**អព្ភូតហេតុមួយទៀត** នៅថ្ងៃ ១៣កើត និង ១៤កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី ២៤ និង ២៥ កញ្ញា ១៩៦៩ នៅវេលាយប់ពីម៉ោង ២០ ទៅម៉ោង ២២ ឃើញព្រះចន្ទ មានរស្មីលឿង ខៀវ ក្រហមមានរង្វង់មូលព័ទ្ធជុំវិញព្រះចន្ទ ដែលយើងធ្លាប់ហៅថា ព្រះចន្ទ័បាំងឆត្រ ។

## ១២-ជីវិតាវសានបរិច្ឆេទ កំណត់អំពីទីបំផុតនៃព្រះជីវិត

រាប់តាំងពីថ្ងៃ ១៣រោច ខែស្រាពណ៍ ជាថ្ងៃដែលទ្រង់ឃើញសុបិន្តនិមិត្ត រហូតមកដល់ថ្ងៃ ១២កើត ខែភទ្របទ គឺត្រូវ នឹងថ្ងៃទី ១០ កញ្ញា មកដល់ថ្ងៃទី ២៣ កញ្ញា ត្រូវជា១៤ថ្ងៃ គឺសម្តេចចាប់មានព្រះអាពាធក្នុងថ្ងៃ ១២កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស ២៥១៣ ត្រូវនឹងថ្ងៃទី ២៣ កញ្ញា ឆ្នាំ១៩៦៩ វេលាម៉ោង ១៥ និង ៤៥ នាទី ។

ព្រះសង្ឃដែលធ្លាប់ចូលគាល់បម្រើព្រះអង្គ នាំគ្នាអង្គុយនៅក្រៅបន្ទប់ក្រឡាព្រះបន្ទំ ស្រាប់តែឮសូរកណ្តឹងរោទ៍ប្លែកធម្មតា ក៏នាំគ្នាស្ទុះចូលទៅក្នុងក្រឡាព្រះបន្ទំភ្លាម ។ គ្រានោះសម្តេចព្រះឱង្ការថា **"ខ្ញុំចុកណាស់ៗ"** ។ ក្នុងពេលនោះព្រះសង្ឃដែលនៅកំដរនោះ ក៏ជំនុំពិគ្រោះ គ្នាឱ្យព្រះសិរីវិសុទ្ធ **ម៉ី យ៉ាំ** និយាយទូរស័ព្ទទៅលោកវេជ្ជបណ្ឌិត **ចៅ ប៉េងចុង** ទៅក្រសួងធម្មការ គ្រូពេទ្យជាច្រើននាក់ គឺលោកវេជ្ជបណ្ឌិត **ចៅ ប៉េងចុង . ម៉ី សាម៉ុឌី . យូ គឹមយាន . ព្រំ កួន . រស សារី** និង លោកវេជ្ជបណ្ឌិត **ម៉ាហ្សូ**

ជាតិបារាំង ក៏បានមកជាបន្ទាន់ៗគ្នា ពិនិត្យឃើញថា អាការរោគនៃសម្តេច មិនទាន់ធ្ងន់ធ្ងរប៉ុន្មានទេ ប៉ុន្តែទោះបីជាយ៉ាងណាក្រសួងសុខាភិបាលក៏បានចាត់ លោកគ្រូពេទ្យ **យូ គឹមយាន** និង **លី គឹមសាន** ឱ្យមកនៅរក្សាព្រះរោគ ប្រចាំការ ប្រកបឱសថថ្វាយជាដរាប រហូតដល់ថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ត្រូវនឹងថ្ងៃ ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០នាទី ស្រាប់តែព្រះអស្សាសៈបស្សាសៈនៃព្រះអង្គ រលត់ស្ងប់ឈឹងអំពីព្រះកាយ ទ្រង់ សោយទិវង្គតក្នុងគម្រប់ព្រះជន្ម ៨៦វស្សា នៅលើព្រះទែនសយនា ដោយស្ងប់ ស្ងៀមនាល្វែងធំ នៅក្នុងព្រះរាជតំណាក់ព្រះអង្គ កណ្តាលពួកថេរានុត្ថេរៈ មានព្រះសិរីវិសុទ្ធ **ម៉ី យ៉ាំ** និងព្រះឥន្ទមុនី **ឆាយ ផន** ជាដើម នាវត្តឧណ្ណា លោម ។ ក្នុងពេលដែលសម្តេចព្រះសង្ឃរាជសោយទិវង្គតភ្លាមនោះ ព្រះសង្ឃ ច្រើនអង្គមានព្រះសិរីវិសុទ្ធ **ម៉ី យ៉ាំ** និងព្រះឥន្ទមុនី **ឆាយ ផន** ជាដើម ព្រមទាំងលោក **មា អ៊ុក** គិលានុបដ្ឋាកក៏នៅកំដរជាមួយដែរ មានចិត្តរំជួល ញាប់ញ័រស្រឡាំងកាំង ស្ទើរភាន់ភាំងស្មារតី បានចាត់ការផ្សាយដំណឹងទិវង្គត ដល់ព្រះសង្ឃក្នុងវត្តភ្លាម អង្គខ្លះក៏រត់ទៅប្រគេនដំណឹងនេះដល់ **សម្តេចព្រះ ពោធិវង្ស** មានព្រះសិរីវិសុទ្ធ **ម៉ី យ៉ាំ** ក៏និយាយទូរសព្ទ័ ទៅលោកវេជ្ជបណ្ឌិត **ចៅ ប៉េងចុង** ទៅព្រះរាជតំណាក់ចម្ការមន ទៅក្រសួងធម្មការ ទៅសាលា ក្រុង ទៅស្នងការដ្ឋានប៉ូលិសភ្លាមៗ លោកអង្គខ្លះក៏យកដំណឹងនេះទៅវត្តឯ ទៀតៗ ក្នុងក្រុងភ្នំពេញ ។

បន្ទាប់ពីបានដំណឹង នៃការសោយព្រះទីវង្គត **នៃសម្តេចព្រះសង្ឃរាជ** ជាអម្ចាស់ភ្លាមក្នុងរាត្រីនោះ **សម្តេចព្រះប្រមុខរដ្ឋ** ទ្រង់បានស្តេចយាងរលះរលាំងមកកាន់មហាកុដិ វត្តឧណ្ណាលោមភ្លាម ដើម្បីក្រាបថ្វាយបង្គំព្រះបរមសព សម្តេចព្រះពោធិវង្សក៏និមន្តមកគង់នៅជិតព្រះបរមសពតាំងពីមើលមុន សម្តែងព្រះសមានទុក្ខសោកស្តាយយ៉ាងខ្លាំងចំពោះព្រះបរមសព ។ ដំណាលគ្នានេះ **សម្តេចព្រះមហាក្សត្រីយានី** ជាអម្ចាស់ជីវិត ក៏ទ្រង់ស្តេចចាត់អ្នកអង្គម្ចាស់នាយកក្រសួងនានា ក្នុងព្រះបរមរាជវាំង ជាព្រះតំណាងមកថ្វាយបង្គំព្រះបរមសពដែរ ហើយពេលជាមួយគ្នានោះ ឯកឧត្តម **អ៊ឹង ហុងសាធ** ឧបនាយករដ្ឋមន្ត្រីទី២ ឯកឧត្តម **ចេង ហេង** ប្រធានរដ្ឋសភា ព្រមទាំងសមាជិក ឯកឧត្តមឧត្តមសេនីយឯក **លន់ នល់** នាយករដ្ឋមន្ត្រី អ្នកអង្គម្ចាស់ស៊ីសុវត្ថិ **សិរិមតៈ** ឧបនាយករដ្ឋមន្ត្រីទី១ ព្រមទាំងសមាជិករដ្ឋមន្ត្រី ឧកញ៉ាមហាមន្ត្រី **កែ មាស** ចាងហ្វាងពិធីការព្រះបរមរាជវាំង និង មន្ត្រីនានាក្នុងព្រះបរមរាជវាំង ឧត្តមសេនីយឯក **ង៉ោ ហ៊ូ** ទីប្រឹក្សាសម្តេចព្រះប្រមុខរដ្ឋ លោក **ឌី ទូច** រដ្ឋលេខាធិកាក្រសួងធម្មការ លោក **អ៊ី ទុយ** អភិបាលក្រុងភ្នំពេញ ឯកឧត្តម **ទឹម ដុង** ប្រតិភូរាជរដ្ឋាភិបាល ប្រចាំខេត្តកណ្តាល ព្រមទាំងនាយទាហានជាន់ខ្ពស់ទាំងឡាយ សហជីវិន **លាង ហ៍បអាន** នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រុមអភិបាលពុទ្ធិកសមាគមទាំង៣ មានលោក **ទា ប៊ុនឡុង** ជាដើម ។

អស់លោក-អ្នកឥស្សរជនធំ-តូច ដែល អញ្ជើញមកកាន់វត្តឧណ្ណាលោម ក្នុងវេលារាត្រី ១៤កើត ខែភទ្របទ ត្រូវនឹង ថ្ងៃទី ២៥ កញ្ញានោះ សុទ្ធតែមានមុខស្រពោន ក្រៀមក្រំគ្រប់ៗគ្នា ដោយសេចក្ដីសោកស្ដាយចំពោះសម្ដេចដ៏ក្រៃលែង បានចូលមកសម្ដែងមរណទុក្ខសោកស្ដាយក្រៀមក្រំរំជួលចំពោះបរមសពដោយគ្រប់គ្នាទាំងអស់ ។ បន្ទាប់បន្តពីនោះមក ព្រះសង្ឃជាច្រើនអង្គ មានព្រះ **ពុទ្ធឃោសាចារ្យ រាជ គឹង** មេគណក្រុងភ្នំពេញ និង **ព្រះមុនីកោសល្យ សួរ ហាយ** ចៅអធិការវត្ត និរោធរង្សីជាដើម ព្រមទាំងព្រះរាជាគណៈ និងថនានុក្រមជាច្រើនរយអង្គនិមន្តមកព្រោងព្រាត សុទ្ធតែមានមុខក្រៀមក្រំ ស្រងូតស្រងាត់គ្រប់ៗអង្គ ដោយសេចក្ដីស្ដាយស្រណោះអាឡោះអាល័យ ចំពោះសម្ដេចជាអម្ចាស់ ។

លំដាប់តរៀងមក ក្នុងពេលរាត្រីនោះរវាងម៉ោង ២២-២៣ ចេះតែមានពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ និមន្ត អញ្ជើញមកកាន់វត្តឧណ្ណាលោមរឿយៗ នាំគ្នាឈរតៀបក្រាពាសពេញដីបរិវេណព្រះរាជតំណាក់ទាំងអស់លោក-អ្នករាជការក្រុងភ្នំពេញ មានលោកអ្នកក្រសួងជាដើម បាននាំគ្នាមកជាលំដាប់លំដោយ ចូលក្រាបថ្វាយបង្គំគាល់ព្រះបរមសព សុទ្ធតែមានទឹកមុខជ្រប់ស្រពោនស្មើរតែគ្រប់គ្នា ខ្លះមានជលនេត្រស្រក់ស្រោករកហានិយាយស្ដីអ្វីពុំកើត ។ ពេលជាលំដាប់មកទៀត ចេះតែមានពុទ្ធបរិស័ទទាំងគ្រហស្ថបព្វជិតធ្វើដំណើរមកកាន់វត្តឧណ្ណាលោម យ៉ាងណែនណាន់តាន់តាប់រហូតទល់តែភ្លឺ ។ លោកអ្នកខ្លះមានទឹកភ្នែកហូររហាមហើយបន្លឺវាចារថ្ងូរថា :

ឱសម្តេចព្រះសង្ឃរាជ! ចូលទិវង្គតហើយតើ! សូម្បីព្រះអង្គមានព្រះជន្ម ៨៦ ពិតមែន ប៉ុន្តែយើងខ្ញុំព្រះអង្គនៅតែស្តាយស្រណោះ ចង់ឱ្យសម្តេចគង់នៅជាងរយព្រះវស្សា ដោយយើងខ្ញុំព្រះអង្គធ្លាប់ ស្តាប់ព្រះរាជឱវាទ ធ្លាប់ឃើញ ធ្លាប់គោរពសម្តេចជាអម្ចាស់ ឥឡូវនេះស្រាប់តែសម្តេចជាអម្ចាស់ចូលទីវង្គតទៅកាន់បរលោកនាយចោលយើងខ្ញុំទៅហើយ ។ ការចូលទីវង្គត នៃសម្តេចព្រះសង្ឃរាជនេះ នាំឱ្យទូលព្រះបង្គំគ្រប់រូបរហេងរហាង ត្រមង់ត្រមោចក្នុងចិត្តអស់សេចក្តីសង្ឃឹមកក់ក្តៅចំពោះសម្តេចទៅហើយ ។

**សម្តេចព្រះសង្ឃរាជ** ដែលព្រះអង្គបានយាងមកសោយព្រះជាតិក្នុងប្រទេសកម្ពុជាយើងនេះ ព្រះអង្គបានធ្វើប្រយោជន៍ ទាំងផ្លូវព្រះពុទ្ធសាសនា ទាំងផ្លូវលោកទុកអោយពុទ្ធបរិស័ទជាច្រើនណាស់ ឈ្មោះថាព្រះអង្គបានលើកព្រះពុទ្ធសាសនា លើកប្រទេសជាតិ ឱ្យបានថ្កុំថ្កើងរុងរឿងរួមជាមួយនឹងសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ដែលយឺតយោងពលរដ្ឋ ដោយព្រះមធ្យោបាយដ៏ខ្ពង់ខ្ពស់បំផុតឱ្យប្រទេសជាតិមានឯកភាព សាមគ្គីភាព សន្តិភាពបានឯករាជ្យដ៏បរិបូរណ៍ដូចសេចក្តីប្រាថ្នា ហើយយ៉ាងណាសម្តេចព្រះសង្ឃរាជមានព្រះរាជជីវប្រវត្តិល្អណាស់ មានព្រះបំណងសម្រេចក៏យ៉ាងនោះដែរ ។

ព្រឹកឡើងថ្ងៃ ១៥កើត ខែភទ្របទ(២៦កញ្ញា) អស់លោកឥស្សរជនបានប្រជុំតាំងគណៈកម្មការមួយបណ្តោះអាសន្ន សម្រាប់ចាត់ការបុណ្យព្រះបរមសពតទៅ ។

## រយៈកាលមុនអំពីកាលដែលទ្រង់សោយទីវង្គត

**សម្តេចព្រះសង្ឃរាជ** មានព្រះអាពាធជាដំបូងក្នុងថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ត្រូវនឹងថ្ងៃទី ២៣ កញ្ញា ឆ្នាំ១៩៦៩ ។ ដំណឹងព្រះអាពាធនៃសម្តេចព្រះសង្ឃរាជនេះ បានថ្វាយចំពោះសម្តេចព្រះប្រមុខរដ្ឋរួចហើយ ឯកឧត្តម **អ៊ឹង ហុងសាធ** តាមព្រះរាជបញ្ជានៃសម្តេចព្រះប្រមុខរដ្ឋ បានចាត់ឱ្យអស់លោកវេជ្ជបណ្ឌិតខ្មែរ-បារាំង ដ៏ជំនាញៗទាំងឡាយ មកជួយខ្វល់ខ្វាយព្យាបាលរោគព្រះអង្គយ៉ាងពេញសមត្ថភាព ប៉ុន្តែធ្វើម្តេចឡើយ នឹងអាចយកជ័យជំនះលើមច្ចុសង្គ្រាមបាន ។

**សម្តេចព្រះសង្ឃរាជ** ជាអម្ចាស់ទ្រង់បានជ្រាបព្រះអង្គមុនចាប់តាំងពីថ្ងៃប្រឈួន ទ្រង់មានព្រះឱង្ការប្រាប់ព្រះសង្ឃ និងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា **"ខ្ញុំ-អាត្មាមានជម្ងឺម្តងនេះ ដូចជាគ្មានសង្ឃឹមទេ"** ព្រះរាជឱង្ការនេះ ធ្វើឱ្យយើងរាល់គ្នាមានការព្រួយបារម្ភណាស់ ប៉ុន្តែយើងរាល់គ្នាជឿងទុកថា : ព្រះអង្គមុខជានឹងគង់ព្រះជន្មាយុតទៅទៀតបាន ពីព្រោះសង្កេតទៅព្រះសរីរាង្គកាយព្រះអង្គ ពុំឃើញមានប្រែប្រួលប្លែកប៉ុន្មានទេ ម្យ៉ាងទៀងទ្រង់នៅចាំព្រះស្មារតីល្អណាស់ អាចមានព្រះឱង្ការមាំមួនសំណេះសំណាលនឹងអស់លោក ទាំងព្រះសង្ឃ-គ្រហស្ថដែលមកក្រាបថ្វាយបង្គំគាល់នោះ បានស្រួលនៅឡើយ ជាពិសេសកាលពីព្រឹកនៃថ្ងៃសោយព្រះទីវង្គតនេះ ឯកឧត្តមនាយករដ្ឋមន្ត្រី និងអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១ បានចូលក្រាបបង្គំព្រះអង្គដើម្បីសាកសួរព្រះរោគព្រះអង្គផង ដើម្បីក្រាបបង្គំលាព្រះអង្គទៅកាន់បរទេស

តាមការអញ្ជើញនៃសាធារណរដ្ឋប្រជាមានិត និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ផង ។ គ្រានោះ ព្រះអង្គបានទទួលរាក់ទាក់ ហើយបានប្រសិទ្ធពរជូនចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី និងថ្វាយចំពោះអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១ សូមទៅបំពេញបេសសកម្មនៅប្រទេសគេបានជោគជ័យ ។ ក្រោយមកទៀត សម្តេចក៏បានព្រះរាជប្រទានសន្ទនាជាមួយលោក **ឌី ទូច** រដ្ឋលេខាធិការ ក្រសួងធម្មការ និងលោក **ទ្រិញ ភ័ញ** ប្រធានសមាគមអ្នកនិពន្ធខ្មែរអំពីការធ្វើចេតិយ៍ ។ ព្រះអង្គមានព្រះបន្ទូលហួរហែ ហើយទ្រង់និទានអំពីចេតិយ៍ឈ្មោះ **សិង្គុត្តរ:** នៅសហភាពភូមាថែមទៀតផង ។ រួចព្រះអង្គត្រាស់រំលឹកអំពីការបោះពុម្ពវចនានុក្រមខ្មែរ ដែលទ្រង់បានខិតខំកែសម្រួលបន្ថែមពាក្យជាច្រើនទៀត ទោះបីជរានិងព្យាធិចេះតែបៀតបៀនព្រះអង្គក៏ដោយ ។ សភាពទាំងនេះសអោយឃើញថា ព្រះអង្គនៅរឹងប៉ឹងណាស់ មិនគួរឡើយនឹងប្រែប្រួលដោយឆាប់រហ័សដូច្នេះសោះ នាំឱ្យយើងក្រៀមក្រំស្រងាកចិត្ត ដូចជាយើងធ្លាក់បេះដូង ។ នេះហើយសមដូចព្រះថេរដីការបស់ព្រះអង្គ ដែលទ្រង់ត្រាស់ជារឿយ១ថា : ជួនកាលពេលព្រឹក មនុស្សសត្វជួបគ្នារញ្ជង់ លុះពេលល្ងាច ក៏ស្រាប់តែបែកគ្នាភ្លាម១ ។ សភាពនេះត្រូវដូចព្រះតម្រាស់នោះណាស់ ។ ព្រះអង្គយាងទៅចោល ពុទ្ធបរិស័ទរាល់គ្នា ឥតមានប្រទានដំណឹងជាមុនឱ្យច្បាស់ដល់យើង ដើម្បីនឹងព្យាបាល ព្រះអាការរោគអោយបានយូរថ្ងៃសោះ គួរអោយយើងខ្ញុំស្តាយក្រៃពេកណាស់ និងរកពាក្យណាមួយថ្លែងរៀបរាប់ពុំបានឡើយ ។ ព្រះអង្គសោយទិវង្គតនេះធ្វើឱ្យរញ្ជួយសកលកម្ពុជា

ព្រោះព្រះអង្គមានព្រះគុណធម៌ច្រើនណាស់លើពុទ្ធបរិស័ទ ទាំងបុព្វជិត ទាំងគ្រហស្ថ ។ សម្តេចសោយព្រះទីវង្គត បាត់ព្រះរូបពិតមែន ប៉ុន្តែព្រះកិត្តិនាមឋិតនៅដដែល ។

អស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ! ព្រះបរមសពនៃសម្តេចព្រះសង្ឃរាជនេះ ជាព្រះសពត្រូវតម្កល់ទុកតាមផ្លូវការរាជរដ្ឋាភិបាល ដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃតទៅ ទំរាំគណៈកម្មការបុណ្យជំនុំគ្នាដោះស្រាយរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព កំណត់យកថ្ងៃណា ខែណាតទៅជាក្រោយ ។ ឥឡូវនេះគណៈកម្មការបុណ្យបណ្តោះ អាសន្នបានព្រមព្រៀងគ្នាកំណត់យកថ្ងៃ ១រោច ខែភទ្របទ ត្រូវ នឹងថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ១៦៩៩ ជាកិច្ចធ្វើទក្ខិណានុប្បទាន មានទេសនា និងវេរភត្តរៀងរាល់យប់ថ្ងៃតរៀងទៅ ចំនួន៦ខែ គិតពីខែនេះទៅ ក្រោមព្រះរាជអធិបតីភាពនៃសម្តេចព្រះមហាក្សត្រីយានី និង សម្តេចព្រះប្រមុខរដ្ឋ ។



សម្តេចព្រះមហាសុមេធាធិបតី គណៈមហានិកាយ

ហួត តាត

## ៥. សម្តេចព្រះសុមេធាធិបតី

## ហួត តាត

## ព្រះសង្ឃរាជ គណៈមហានិកាយ

## ព.ស ២៥១៣-គ.ស ១៩៦៩

## ព.ស ២៥១៩-គ.ស ១៩៧៥

-ព្រះអង្គប្រសូត នៅថ្ងៃអាទិត្យ ១៥កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស ២៤៣៥ គ.ស ១៨៩២ នៅភូមិផ្សារឧដុង្គ ខេត្តកំពង់ស្ពឺ ។ បីតានាម ហុក សេង ហៅ ហួត មាតា នាម ង៉ែត ។

-ព្រះជន្មាយុបាន ៧ឆ្នាំ បានទៅរៀនអក្សរសាស្ត្រ លេខនពន្ត ក្នុងសំណាក់ ព្រះធម្មឃោសាចារ្យ **មាស** ។

-ព្រះជន្មាយុបាន ១៣ឆ្នាំ បួសជាសាមណេរ នៅក្នុងសំណាក់ព្រះធម្មឃោសាចារ្យ ។ ព្រះអង្គបានសិក្សា ព្រះបរិយត្តិធម៌ ក្នុងសំណាក់ព្រះធម្មលិខិត **ស៊ូ** ។

-ព្រះជន្មាយុបាន ២១វស្សា នៅឆ្នាំជូត ព.ស ២៤៥៦ គ.ស ១៩១២ បានឧបសម្បទាក្នុងពទ្ធសីមាវត្តឧណ្ណាលោម ក្នុងសំណាក់សម្តេចព្រះសង្ឃរាជ ព្រះនាម **និល ទៀង** ជាព្រះឧបជ្ឈាយ៍ ។

-ព្រះជន្មាយុបាន ៥៧វស្សា នៅឆ្នាំជូត ព.ស ២៤៩២ គ.ស ១៩៤៨ ព្រះអង្គបាន ទទួលសមណស័ក្តិជា **ព្រះពោធិវ័ង្ស** ។

-ព្រះជន្មាយុបាន ៧៣វស្សា នៅឆ្នាំរោង ព.ស ២៥០៨ គ.ស ១៩៦៩ ព្រះអង្គបានទទួលសមណស័ក្តិជា **សម្តេចព្រះពោធិវង្ស** តាមព្រះរាជក្រឹត្យលេខ ២៤ រ.វ ចុះថ្ងៃទី ២៤ កក្កដា ១៩៦៤ ។

-ព្រះជន្មាយុបាន ៧៨វស្សា នៅឆ្នាំរកា ព.ស ២៥១៣ គ.ស ១៩៦៩ ព្រះអង្គបាន ទទួលសមណស័ក្តិជា **សម្តេចព្រះមហាសុមេធាធិបតី** ព្រះសង្ឃនាយក គណៈមហានិកាយ ។

-ព្រះជន្មាយុបាន ៧៩វស្សា នៅឆ្នាំច ព.ស ២៥១៤ គ.ស ១៩៧០ ព្រះអង្គបាន ទទួលសមណស័ក្តិជា **សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ** គណៈមហានិកាយ ពីឯកឧត្តម **ចេង ហេង** ប្រធានសភាជាតិ ។

-ក្នុងឆ្នាំថោះ ព.ស ២៥១៩ គ.ស ១៩៧៥ ព្រះអង្គបានចូលទីវង្គត ក្នុងព្រះជន្មាយុ ៨៤វស្សា ។



សម្តេចព្រះមហាសុមេធាធិបតី គណៈមហានិកាយ

ទេព វង្ស

## ៦. សម្តេចព្រះមហាសុមេធាធិបតី

## ទេព វង្ស

## ព្រះសង្ឃរាជ គណៈមហានិកាយ

## ព.ស ២៤៣៤ គ.ស ១៩៩១

-ព្រះអង្គប្រសូត នៅថ្ងៃព្រហស្បតិ៍ ១រោច ខែបុស្ស ឆ្នាំវក ចត្វាស័ក ព.ស ២៤៧៦ ត្រូវនឹងថ្ងៃទី១២ ខែមករា គ.ស ១៩៣២ នៅភូមិត្រពាំងចក ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ។ មាតា នាម **ប៉ិច អាត់** បិតា នាម **ទេព ឈិត** ។

-ព្រះជន្មាយុបាន ១០ឆ្នាំ នៅឆ្នាំម្សាញ់ ត្រីស័ក ព.ស ២៤៨៥ គ.ស ១៩៤១ ព្រះមាតាបិតា បាននាំកុមារ **ទេព វង្ស** ឱ្យទៅនៅវត្តរាជបូព៌ ដើម្បីរៀនអក្សរ លេខនពន្ត ក្រោមការគ្រប់គ្រងរបស់ព្រះគ្រូសមុហ៍គណ **ហ៊ីង ម៉ៅ** ចៅអធិការវត្តរាជបូព៌ ។

-ព្រះជន្មាយុបាន ១៦ឆ្នាំ នៅឆ្នាំកុរ នព្វស័ក ព.ស ២៤៩១ គ.ស ១៩៤៧ បានបួសជាសាមណេរនៅក្នុងសំនាក់ព្រះគ្រូសមុហ៍គណព្រះគ្រូចៅអធិការវត្តរាជបូព៌ ជាព្រះឧបជ្ឈាយ៍ ។

-ការបួសជាសាមណេរបានត្រឹមតែ៩ខែទេ សូមលាចាកសិក្ខាបទមករកស៊ីចិញ្ចឹមព្រះមាតាវិញ ។

-ព្រះជន្មាយុបាន ២១វស្សា នៅឆ្នាំរោង ចត្វាស័ក ព.ស ២៤៨៦ គ.ស ១៩៤២ បានទៅបំពេញឧបសម្បទា នៅក្នុងសំណាក់ព្រះគ្រូសមុហ៍គណ **ហ៊ីង ម៉ៅ** ជាព្រះឧបជ្ឈាយ៍នៅក្នុងពុទ្ធសីមាវត្តរាជបូព៌ ។

-ព្រះជន្មាយុបាន ២៩វស្សា នៅឆ្នាំវក ព.ស ២៥០០ គ.ស ១៩៥៦ ព្រះគ្រូសមុហ៍ គណ **ហ៊ីង ម៉ៅ** បានតែងតាំងភិក្ខុ **ទេព វង្ស** ឱ្យធ្វើជាគ្រូសូត្រជំនួយការ ។

-ព្រះជន្មាយុបាន ៤៨វស្សា នៅពេលប្រជាជនខ្មែរ បានរួចផុតពីរបប ប៉ុល ពត ព្រះអង្គបាននិមន្តមកបួសឡើងវិញ នៅថ្ងៃ ១៣រោច ខែភទ្របទ ឆ្នាំមមែ ឯកស័ក ព.ស ២៥២៣ ត្រូវនឹងថ្ងៃទី ១៩ ខែកញ្ញា គ.ស ១៩៧៩ ។ ពេលបួសរួច ព្រះឧបជ្ឈាយ៍ បានប្រកាសនៅក្នុងជំនុំសង្ឃថា ភិក្ខុ ទេព វង្ស អោយឡើងឋានានុក្រម មានឋានន្តរស័ក្តិជាព្រះគ្រូវិន័យធរ ។

-ព្រះជន្មាយុបាន ៦០វស្សា ព្រះអង្គបានទទួលសមណស័ក្តិជា **សម្តេចព្រះមហាសុមេធាធិបតី** ព្រះសង្ឃនាយក គណៈមហានិកាយ នៅថ្ងៃសុក្រ ២កើត ខែកត្តិក ឆ្នាំមមែ ត្រីស័ក ព.ស ២៥៣៥ ត្រូវនឹងថ្ងៃទី ៨ វិច្ឆិកា គ.ស ១៩៩១ ។

-នៅក្នុងព្រះជន្មាយុ៦០វស្សានេះដែរ ព្រះអង្គបានទទួលសមណស័ក្តិជា សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណៈមហានិកាយ

នៅថ្ងៃសុក្រ ៩កើត ខែកត្តិក ឆ្នាំមមែ ត្រីស័ក ព.ស ២៥៣៥ ត្រូវនឹងថ្ងៃ ១៥ ខែវិច្ឆិកា គ.ស. ១៩៩១ ។



សម្តេចព្រះសុគន្ធាធិបតី គណៈធម្មយុត្តិកនិកាយ

**បញ្ញាសីលោ ប៉ាន**

# ១. ប្រវត្តិរបសខេ្ទប
# នៃ
# សម្តេចព្រះសុគន្ធាធិបតី បញ្ញាសីលោ ផាន
# គណៈធម្មយុត្តិកនិកាយ
# ព.ស ២៤០១-២៤៣៦
# គ.ស ១៨៥៧-១៨៩៣

សម្តេចព្រះសុគន្ធាធិបតី **ផាន** សម្តេចសម្ភព នៅថ្ងៃព្រហស្បតិ៍ ១រោច ខែកត្តិក ឆ្នាំ ចរ អដ្ឋស័ក ព.ស ២៣៧០ គ.ស ១៨២៦ ច.ស ១១៨៨ នៅភូមិព្រែក ព្រះស្តេច ខេត្តបាត់ដំបង ។ ឯស្រុកកំណើត មាតាបិតា នៃសម្តេចនៅភូមិស្មោង ខេត្ត កំពង់ធំ ។ ឯកសារទាំងអស់នេះមិនបានបញ្ជាក់ពី ឈ្មោះនៃមាតាបិតាសម្តេចទេ ។ព្រះមាតាបិតាសម្តេច បានរត់ទៅនៅខេត្តបាត់ដំបង ពីព្រោះមានការកើតចលាចលនៃ **ឧកញ៉ាតេជោ ឌែន** តែនៅក្នុងប្រវត្តិសាស្ត្រខ្មែរ របស់លោក រស់ ចន្ទ្រាបុត្រ កាលសម័យព្រឹត្តិការណ៍ បងប្អូន មូ នាំគ្នាបង្កើតចលាចល(គ.ស១៧៧៩-១៧៨៨) ។

កាលសម្តេចព្រះជន្ម ១២វស្សា (ឆ្នាំរកា នពស័ក ព.ស២៣១៨ គ.ស ១៨៣៧ ម.ស ១៧៥៩ ច.ស ១១៩៩) បានបុព្វជ្ជាជាសាមណេរ នៅវត្តពោធិ៍ ឃុំសង្កែ ខេត្តបាត់ដំបង គណៈមហានិកាយ ។

ព្រះអង្គបាននិមន្តចូលនៅក្រុងថេព ប្រទេស ថៃ គង់នៅវត្តសាកេត គណៈមហានិកាយ ។

លុះដល់ព្រះជន្មាយុ ២១វស្សា បានឧបសម្បទាជាភិក្ខុគណៈមហានិកាយ គង់នៅវត្តសាកេត បាន៨វស្សា ។ នៅពេលនោះ ក្រុមម៉ឺន ភូវឱន ជាជីដូន បាននាំសម្ដេច ទៅថ្វាយសម្ដេចព្រះ**ចមក្លាវ** ។សម្ដេចព្រះ **ចមក្លាវ** ឱ្យសិក្សាសិក្ខាវិន័យ ក្នុងតំណាក់ចៅឃុនព្រះញាណរក្ខិត សុត ចៅអធិការវត្តបរមនិវាសន៍ គណៈធម្មយុត្ត ។

លុះកន្លងមក នៅថ្ងៃ១រោច ខែអាសាធ ឆ្នាំរកា ឯកស័ក ព.ស ២៣៩៣ គ.ស ១៨៤៩ ម.ស ១៧៧១ ច.ស ១២១១ សម្ដេចមានព្រះជន្ម ២៨វស្សា បានចូលឧបសម្បទាជាភិក្ខុ ក្នុងគណៈធម្មយុត្ត ។ សម្ដេចព្រះ **ចមក្លាវ** ជាព្រះឧបជ្ឈាយ៍ ចៅឃុនញាណរក្ខិត លុត ជាកម្មវាចាចារ្យ អមរាភិរក្ខិត កើតជាអនុស្សាវនាចារ្យ បាននាមឆាយាថា **បញ្ញាសីលោ** ។

នៅក្នុងឆ្នាំ ១៨៥៦ បានសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង** បានធ្វើព្រះរាជសុភអក្សរ ថ្វាយព្រះចៅក្រុងសៀម សូមព្រះអង្គទ្រង់ព្រះរាជានុញ្ញាតឱ្យព្រះមហា **ប៉ាន** បានវិលត្រលប់មកប្រទេសកម្ពុជាវិញ ។

ពេលនោះ សម្ដេចព្រះ ចមក្លាវ ទ្រង់ព្រះរាជានុញ្ញាត ព្រមទាំងទ្រង់អារាធនា ចៅឃុនព្រះអមរាភិរក្ខិត កើត នឹងព្រះសង្ឃ៨អង្គ ឧបាសក

៨នាក់ ឱ្យជូនព្រះមហា **ប៉ាន** មកគង់នៅប្រទេសកម្ពុជា ក្នុងឆ្នាំខាល ឆស័ក ព.ស ២៣៩៨ គ.ស ១៨៥៤ ម.ស ១៧៧៦ ច.ស ១២១៦ ។

ព្រះបាទសម្តេចព្រះ អង្គឌួង ទ្រង់និមន្តព្រះមហា **ប៉ាន** ឱ្យគង់នៅវត្តសាលាគូ (វត្តអំពិលបី) ក្រុងឧត្តុង្គមានជ័យ ។ ព្រះមហា **ប៉ាន** បានឡើងសមណស័ក្តិ :

១. ព្រះអរិយវង្ស

២. ព្រះវិមលធម្ម

៣. ព្រះមហាវិមលធម្ម

៤. សម្តេចព្រះសុគន្ធាធិបតី

ព្រះសង្ឃនាយក(មានព្រះរាជបញ្ញត្តិឱ្យទូលឆ្លើយ ដោយពាក្យព្រះរាជស័ព្ទទាំងអស់) ។

**បញ្ជាក់ :**

ព្រះមហា **ប៉ាន** បានឡើងជាសម្តេចព្រះសុគន្ធាធិបតី ព្រះសង្ឃនាយក ពីឆ្នាំម្សាញ់ នព្វស័ក ព.ស២៤០១ គ.ស១៨៥៧ ម.ស១៧៧៩ ។

សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយក ប៉ាន ព្រះអង្គទ្រង់សោយទីវង្គត នៅថ្ងៃ សៅរ៍ ៤រោច ខែមាឃ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស ២៤៣៧ ម.ស ១៨១៥ ក្នុងព្រះជន្ម គំរប់ ៦៧វស្សា ។

**កំណត់សំគាល់**

នៅក្នុងសៀវភៅតែមួយមានឈ្មោះមិនឯកភាពសោះ



សម្តេចព្រះមង្គលទេពាចារ្យ គណៈធម្មយុត្តិកនិកាយ

ភទ្ទគូ អៀម

# ២. ប្រវត្តិសង្ខេប

# នៃ

# សម្តេចមង្គលទេពាចារ្យ ព្រះនាម អៀម

# ព.ស ២៤៣៧-២៤៦៥

# គ.ស ១៨៩៤-១៩២២

សម្តេចសម្ភព នៅថ្ងៃអាទិត្យ ខែផល្គុន ឆ្នាំរកា ឯកស័ក ព.ស ២៣៩៣ គ.ស ១៨៤៩ ម.ស ១៧៧១ ច.ស ១២១១ នៅភូមិព្រៃពួច ស្រុកសំរោងទង ខេត្ត កំពង់ស្ពឺ ។ មាតានាម អ៊ុក បិតានាម ម៉ឹង ។

សម្តេចព្រះជន្ម ៨ឆ្នាំ បានរៀនអក្សរសាស្ត្រខ្មែរ ក្នុងសំណាក់លោកគ្រូសូត្រ ទេព នៅវត្តព្រៃពួច ឃុំស្រុកកំណើត គណៈមហានិកាយ ។ លុះដល់ព្រះជន្ម ១៣វស្សា បានបព្វជ្ជាជាសាមណេរ នៅវត្តព្រៃពួច នោះបាន២វស្សា បានចាកសិក្ខាបទមកវិញ ទើបលោកឧកញ៉ា សុភាធិបតី ម៉ា ត្រូវជាឪពុកធំនៃសម្តេចបង្កើត បាននាំទៅថ្វាយសម្តេច ព្រះសុគន្ធាធិបតី **ប៉ាន** គង់នៅវត្តសាលាគូក្រុងឧត្តុង្គមានជ័យ ។

លុះដល់ព្រះជន្ម ២២វស្សា មមី ទោស័ក ព.ស២៤១៤ គ.ស ១៨៧០ ម.ស ១៧៩២ ច.ស ១២៣២ បានឧបសម្បទាជាភិក្ខុដែលមានសម្តេចព្រះសុគន្ធាធិបតី **ប៉ាន** ជាព្រះឧបជ្ឈាយ៍. ព្រះពោធិវង្ស **ចាន់** ចៅអធិការវត្តស្វាយពពែ ជាកម្មវាចារ្យ. ព្រះធម្មមុន្នី **ទេព** ជាអនុស្សវនាចារ្យ បាននាមឆាយាជា **គន្ធគុ** ក្នុងសីមាវត្តបុទមវតី ក្រុងភ្នំពេញ ។

អំពីសមណស័ក្តិ នៃសម្តេច :

១. ព្រះចៅអធិការបទុមវតី សង្ឃនាយកស្តីទី

២. សម្តេចព្រះវនរតន៍ ទីសង្ឃនាយក

៣. សម្តេចព្រះមង្គលទេពាចារ្យ ទីសង្ឃនាយក ។

សម្តេចព្រះមង្គលទេពាចារ្យ ព្រះនាម **អៀម** បានទទួលនាទីជា **សម្តេចព្រះ មង្គលទេពាចារ្យ** ពីឆ្នាំវក សំរឹទ្ធិស័ក ព.ស ២៤៥២ គ.ស១៩០៩ ម.ស ១៨៣០ ច.ស ១២៧០ ក្នុងព្រះជន្មគំរប់ ៦០ឆ្នាំ។

សម្តេចព្រះមង្គលទេពាចារ្យព្រះនាម **អៀម** បានទីវង្គត នៅថ្ងៃព្រហស្បតិ៍ ១រោច ខែមិគសិរ ឆ្នាំចរ ចត្វាស័ក ព.ស ២៤៦៦ គ.ស ១៩២២ ម.ស ១៨៤៤ ច.ស ១២៨៤ វេលាម៉ោង ៩ព្រឹក ក្នុងព្រះជន្ម ៧៤វស្សា ។



សម្តេចព្រះមង្គលទេពាចារ្យ គណៈធម្មយុត្តិកនិកាយ

បញ្ញាទីបោ ស៊ុក

## ៣. ប្រវត្តិសង្ខេប

## នៃ

## សម្តេចព្រះមង្គលទេពាចារ្យ ព្រះនាម ស៊ុក

## គណៈធម្មយុត្តិកនិកាយ

## ព.ស ២៤៦៦-២៤៨៥

## គ.ស ១៩២៣-១៩៤២

សម្តេចសម្ភព នៅថ្ងៃព្រហស្បតិ៍ ខែមាឃ ឆ្នាំរកា ត្រីស័ក ព.ស ២៤០៥ គ.ស ១៨៦១ ម.ស ១៧៨៣ ច.ស ១២២៣ ក្នុងស្រុកនគររាជ ប្រទេសថៃ ។ បិតានាម អៀម . មាតានាម មៅ មាតាបិតាចុះមករស់នៅភូមិរុន ស្រុកក្រលាញ់ ខេត្តបាត់ដំបង វិញកាលខេត្តនេះនៅក្រោមអំណាចប្រទេសថៃ ។

កាលនៅពីកុមារ សម្តេចសិក្សាអក្សរសាស្ត្រខ្មែរ នៅវត្តសំពៅលូន ភូមិរុន ស្រុក ក្រលាញ់ ។ លុះដល់ព្រះជន្ម ២១វស្សា ម្សាញ់ ត្រីស័ក ព.ស ២៤២៥ គ.ស ១៨៨១ ម.ស១៨០៣ ច.ស ១២៤៣ សម្តេចបានឧបសម្បទាជាភិក្ខុ គណៈមហានិកាយ នៅវត្តសំពៅលូននោះ ។សម្តេចគង់នៅវត្តសំពៅលូននោះបាន៨វស្សា សិក្សាអក្សរសាស្ត្រថៃ ចេះស្ទាត់ បានចូលមកសុំនៅវត្តបទុមវតី ក្រុងភ្នំពេញ ទាំងភេទជាមហានិកាយនៅក្នុងសំណាក់ព្រះមហាព្រហ្មមុនី ភេត កាលដែលលោកនៅជាមហា៤

ប្រយោគ ។ សម្ដេចបាន សិក្សាធម្មវិន័យជ្រាបផ្លូវវត្តប្រតិបត្តិត្រឹមត្រូវ ហើយក៏និមន្តសម្ដេច ព្រះសុគន្ធាធិបតី **ប៉ាន** ជាព្រះឧបជ្ឈាយ៍ ព្រះមហាបទុម **ឌេព** ជាកម្មវាចារ្យ បាននាមឆាយាជា **បញ្ញាទីបោ** ក្នុងសីមាវត្តបទុមវតី ក្រុងភ្នំពេញ ក្នុងព្រះជន្ម ២៨វស្សា នៅឆ្នាំជូត សំរឹទ្ធស័ក ព.ស ២៤៣២ គ.ស ១៨៨៨ ម.ស ១៨១០ ច.ស ១២៥០ ។

**ឋានៈសមណសក្តិ នៃសម្ដេច :**

១. សង្ឃនាយកស្តីទី

២. ព្រះមង្គលទេពាចារ្យ សង្ឃនាយកស្តីទី

៣. សម្ដេចព្រះមង្គលទេពាចារ្យ

សម្ដេចព្រះមង្គលទេពាចារ្យ ព្រះនាម ស៊ុក ព្រះអង្គបានចូលទីវង្គត នៅថ្ងៃ ព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំមមី ចត្វាស័ក ព.ស ២៤៨៦ គ.ស ១៩៤២ ម.ស ១៨៦៤ ច.ស ១៣០៤ វេលាម៉ោង ១១និង ១៥នាទី អធ្រាត្រ ដោយជរាពាធ ក្នុងព្រះជន្ម ៨២វស្សា ។



សម្តេចព្រះសុធម្មាធិបតី គណៈធម្មយុត្តិកនិកាយ

## ពុទ្ធនាគោ អ៊ុង ស្រី

# ៤. ប្រវត្តិសង្ខេប

# នៃ

# សម្តេចសុគន្ធាធិបតី ព្រះនាម អ៊ុំ ស្រី

# គណៈធម្មយុត្តិកនិកាយ

# ព.ស ២៤៨៥-២៤៩៨

# គ.ស ១៩៤២-១៩៥៦

សម្តេចសម្ភព នៅថ្ងៃទី ៥ ១៣/១/១ (ព្រហស្បតិ៍ ១៣កើត ខែមិគសិរ) ឆ្នាំមមី ទោស័ក ព.ស ២៤១៤ គ.ស ១៨៧០ ម.ស ១៧៩២ ច.ស ១២៣២ បិតានាម **អ៊ុំ** មាតានាម **ណី** ស្រុកកំណើតនៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ព្រះជន្ម ១២ឆ្នាំ បិតាអនិច្ចធម្មចោលទៅ សម្តេចនៅជាមួយម្តាយ ។

ព្រះជន្ម ១៣ឆ្នាំ បានសិក្សាអក្សរសាស្ត្រខ្មែរ នៅក្នុសំណាក់លោកគ្រូ **ឃួន** ចៅអធិការវត្តស្វាយ គណៈមហានិកាយនៅ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ព្រះជន្ម ១៩វស្សា បានបួសជាសាមណេរ ក្នុងសំណាក់លោកគ្រូ **ឃួន** នៅពេលនោះវត្តស្វាយបានផ្លាស់មកជាគណៈធម្មយុត្តវិញ នៅឆ្នាំឆ្លូវ ឯកស័ក ព.ស ២៤៣៣ គ.ស ១៨៨៩ ។ បួសបាន១វស្សាលាចាកសិក្ខាបទ មករស់នៅជាមួយម្តាយវិញ ។

ព្រះជន្ម ២៤ឆ្នាំ បានចូលឧបសម្បទជាភិក្ខុ ក្នុងសំណាក់នៃសម្តេចព្រះសុគន្ធាធិបតី បញ្ញាសីលោ **ផាន** ជាព្រះឧបជ្ឈាយ៍ សម្តេចព្រះមង្គលទេពាចារ្យ **ភទ្ទគូអៀម** កាលនៅជាព្រះមហាព្រហ្មមុនី ជាកម្មវាចាចារ្យ លោកគ្រូ ជៀង ចៅអធិការវត្តព្រែកឫស្សី ជាអនុស្សាវនាចារ្យ បាននាមឆាយាថា ពុទ្ធនាគោ សំរេចញត្តិ ចតុត្ថកម្មវាចាចារ្យ ក្នុងសីមាវត្តបុទុមវតី នៅថ្ងៃទី ៥$^{១៥}_{។/១}$ (ថ្ងៃព្រហស្បតិ៍ ១៥កើត ខែពិសាខ) ឆ្នាំម្សាញ់ បញ្ចស័ក ព.ស ២៤៣៧ គ.ស ១៨៩៣ ម.ស ១៨១៥ ច.ស ១៨៥៥ ។

ព្រះជន្ម ២៥ឆ្នាំ ព្រះវស្សាបាន ៤ និមន្តចេញពីវត្តស្វាយ មកគង់នៅវត្តបទុមវតី ក្នុងឆ្នាំមមែ សប្តស័ក ព.ស ២៤៣៨ គ.ស ១៨៩៥ ម.ស ១៨១៧ ច.ស ១២៥៧ ក្នុងសំណាក់ព្រះគ្រូវិន័យធរ **នុត** ។

**<u>អំពីសមណស័ក្តិ នៃសម្តេច</u> :**

១.ស្តីទី ព្រះសង្ឃនាយក នៅថ្ងៃទី ៥$^{។៦}_{១}$(ថ្ងៃព្រហស្បតិ៍ ទី១រោច ខែពិសាខ) ឆ្នាំមមីចត្វាស័ក ព.ស២៤៨៦ ត្រូវនឹងថ្ងៃទី៣០ មេសា ១៩៤២ ។

២.សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយក នៅថ្ងៃ ៧$^{។៧}_{២}$(ថ្ងៃសៅរ៍ ទី ២រោច ខែជេស្ឋ)ឆ្នាំមមែ បញ្ចស័ក ព.ស២៤៨៧ ត្រូវ នឹងថ្ងៃ ១៩ មិថុនា ១៩៤៣ ។

៣.សម្តេចព្រះសុធម្មាធិបតីព្រះសង្ឃនាយក បានចូលទីវង្គត នៅថ្ងៃចន្ទ ៣រោច ខែមាឃ ឆ្នាំវក អដ្ឋស័ក ព.ស ២៥០០ ត្រូវនឹងថ្ងៃ៣០ មករា ១៩៥៦ ។



សម្តេចព្រះសុធម្មាធិបតី គណៈធម្មយុត្តិកនិកាយ

# ឥន្ទញ្ញាណោ ភុល ទេស

# ៥. ព្រះរាជជីវប្រវត្តិសង្ខេប

## នៃ

## សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជថ្នាក់ទី២

## នៃគណៈធម្មយុត្តិកនិកាយ

## ព្រះនាម ឥន្ទញ្ញាណោ ភុល ទេស

## ព.ស ២៤៩៨-២៥០៩

## គ.ស ១៩៥៦-១៩៦៦

សម្តេចទ្រង់សម្ភពនៅថ្ងៃ១ ១៥ ៩ (ថ្ងៃអាទិត្យ ទី១៥កើត ខែស្រាពណ៍) ឆ្នាំ ថោះ ត្រីស័ក ព.ស ២៤៣៤ (គ.ស ១៨៩១)ក្នុងភូមិ កោះរះ សង្កាត់កោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ។ បិតា នាម ភុល មាតា នាម ទៃ ។

កាលនៅពីកុមារ សម្តេចមានព្រះជន្មាយុ បាន១០ឆ្នាំ ក្នុងឆ្នាំជូត ទោស័ក ព.ស ២៤៤៣ (គ.ស ១៩០០) បានទៅនៅសិក្សាអក្សរសាស្ត្រ ក្នុងសំណាក់លោកគ្រូអាចារ្យ **សំ** វត្តកោះរះ គណៈមហានិកាយ ។

លុះព្រះជន្ម បាន១១ឆ្នាំ ក្នុងឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៤៤៤ (គ.ស ១៩០១) បិតាបាននាំមកអោយនៅវត្តបទុមវតីរាជវរារាម ក្នុងក្រុងភ្នំពេញ ក្នុងសំណាក់ព្រះគ្រូ **ម៉ៅ** ក្រុមព្រះមុនី **កេត** កាលនៅជាព្រះវជិរមេធា ។ លោកបានសិក្សាអក្សរសាស្ត្រជាតិ លេខនពន្ត និងធម្មវិន័យ ចេះចាំស្ទាត់ ល្អមប្រើការបាន ។

លុះជន្មាយុ បាន១៥វស្សា បានចូលបព្វជ្ជា ជាសាមណេរក្នុងវត្តបទុមវតីរាជវរារាម នៅថ្ងៃ៨កើត ខែអាសាធ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៤៤៨ (គ.ស ១៩០៥) ក្នុងសំណាក់សម្តេច ព្រះវន្ន័រត ដែលតមកជាព្រះមង្គលទេពាចារ្យ ជាសង្ឃនាយក ព្រះនាម **ឝន្ទគូ អៀម** ជាព្រះឧបជ្ឈាយ៍ ។

លុះព្រះជន្ម បាន២១វស្សា បានចូលឧបសម្បទាជាភិក្ខុភាវៈ ក្នុងពុទ្ធសីមា វត្តបទុមវតី រាជវរារាម នៅថ្ងៃអាទិត្យ ១៣កើត ខែអាសាធ ឆ្នាំកុរ ត្រីស័ក ព.ស ២៤៥៤ (គ.ស ១៩១១) វេលាម៉ោង៩ព្រឹក ក្នុងសំណាក់ សម្តេចព្រះមង្គលទេពាចារ្យ ព្រះនាម **ឝន្ទគូ អៀម** ជាព្រះឧបជ្ឈាយ៍ បាននាមបញ្ញត្តិថា **ឝន្ទញ្ញាណោ** ។

ទ្រង់ព្រះផ្នួសបាន៤៤ព្រះវស្សា ជន្មាយុបាន ៦៥ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា **ព្រះសុធម្មាធិបតី** សង្ឃនាយកស្តីទី និងជាចៅអធិការវត្តបទុមវតីរាជវរារាម នៅថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំមមែ សប្តស័ក ព.ស ២៤៩៨(៣១-១-១៩៥៦) ។

ទ្រង់ព្រះផ្នួសបាន ៥២ព្រះវស្សា ព្រះជន្មាយុបាន ៦៦វស្សា ទ្រង់បានឡើងសមណស័ក្តិ ជាសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកពេញទីនៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែមាឃ ឆ្នាំរក អដ្ឋស័ក ព.ស ២៤៩៦ ( ២៨-២-១៩៥៧ ) ។

ទ្រង់ព្រះផ្នួសបាន ៥២ព្រះវស្សា ព្រះជន្មាយុបាន ៧៣វស្សា សម្ដេច **ព្រះនរោត្តម សីហនុ ឧបយុវរាជ** ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានប្រោសប្រគេនព្រះឋានៈជា សម្ដេចព្រះសង្ឃរាជ ថ្នាក់ទី២ នៃគណៈធម្មយុត្តិកនិកាយ ដែលជាសមណសក្តិដ៏ខ្ពង់ខ្ពស់បំផុត និងទ្រង់ត្រាស់ឱ្យប្រើរាជស័ព្ទ ចំពោះសម្ដេចព្រះសង្ឃ រាជព្រមទាំងមានប្រសិទ្ធិភាពដូចខាងក្រោម :

- ព្រះសុវណ្ណកោដ្ឋៈពិសេស
- ផ្ចិតស្រួចពិសេស
- រងព្រះសិរពិសេស
- ទង់សំរាប់ព្រះទីនាំងរថយន្ត ពិសេស

ដោយព្រះរាជក្រឹត្យលេខ ២៤ រ.វចុះថ្ងៃទី ២៨ ខែវិច្ឆិកា គ.ស ១៩៦៣ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥០៦ ។

នៅថ្ងៃទី ០២ ខែ មករា គ.ស ១៩៦៦ សម្ដេចទ្រង់បានប្រឈួនជាទំងន់ ដោយព្រះរោគគ្រុន . ព្រះកាសរោគ(រោគក្អក) និងព្រះសាសរោគ(រោគហឺត)មកជៀតជ្រែក លាយឡំគ្នាផង រហូតដល់រាត្រីថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥០៩ ត្រូវនឹងថ្ងៃទី៧ ខែមេសា គ.ស ១៩៦៦ វេលាម៉ោង ២១និង២០នាទី សម្ដេចទ្រង់សោយទីវង្គត ក្នុងព្រះជន្មគំរប់៧៩វស្សា ។



សម្តេចព្រះសុធម្មាធិបតី គណៈធម្មយុត្តិកនិកាយ

គន្ធរោ ទេព លឿង

# ៦.សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជ
# ទេព លឿង
# គណៈធម្មយុត្តិកនិកាយ
# ព.ស ២៥០៩-២៥១៩
# គ.ស ១៩៦៦-១៩៧៥

-ព្រះអង្គសម្ភព ពីថ្ងៃទី០២-០២-១៨៨៣ ឆ្នាំមមែ ព.ស២៤២៧ នៅភូមិវានាម ត្នោត ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ ។ បិតា នាម ង៉ែត មាតា នាម ទូត អុង ។

-ព្រះអង្គបួសរៀន នៅវត្តទេពប្រណម្យ ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ។

ព្រះអង្គបានចាកចេញពីវត្តទេពប្រណម្យមកស្នាក់នៅវត្តនួនមុនីរាម ដើម្បីរៀនបាលី ។ ព្រះអង្គបានទៅនៅរៀនក្នុងប្រទេសថៃ ចំនួន២០ឆ្នាំ ។ ពេលត្រឡប់មកពីប្រទេសថៃ ព្រះអង្គបានមកគង់នៅវត្តនួនមុនីរាម (វត្តថាន់) ក្រុងភ្នំពេញវិញ ។

-ព្រះអង្គបានឡើងជាសង្ឃនាយកស្តីទី គណៈធម្មយុត្តិកនិកាយពីគ.ស ២៥១០ គ.ស ១៩៦៦ ។ បន្ទាប់មក ព្រះអង្គបានឡើងជាសម្តេចព្រះសង្ឃនាយក ។

-ឡើងសម្តេចព្រះសង្ឃនាយក បានជាង១ឆ្នាំ ព្រះអង្គបានចេញពីវត្តនួនមុនីរាម មកគង់នៅវត្តបទុមវតីរាជវរារាមវិញ ។

-នៅព.ស ២៥១៤ គ.ស១៩៧០ ព្រះអង្គបានទទួលឋានន្តរស័ក្តិជាសម្តេចព្រះសង្ឃរាជ ។

-ព្រះអង្គបានសោយព្រះទីវង្គត នៅថ្ងៃទី១៥ ខែមេសា គ.ស១៩៧៥ ក្នុងឆ្នាំថោះ ព.ស២៥១៨ ក្នុងព្រះជន្ម៩៣ឆ្នាំ នៅវត្តបទុមវតី ។ នៅពេលនោះប្រទេសខ្មែរកំពុងតែមានសង្គ្រាម លន់ នល់ និងប៉ុលពតយ៉ាងខ្លាំង ។ នៅពេលនោះ ពុទ្ធបរិស័ទ និងបងប្អូនចេញទៅក្រៅអស់ ។ ពេលបែក ប៉ុល ពត ទៅរកមើលបាត់ទាំងព្រះកោដ្ឋ បាត់ទាំងព្រះបរមសព ។



សម្តេចព្រះសង្ឃនាយក ស្តីទី គណៈធម្មយុត្តិកនិកាយ

ហ៊ី ជា

## ៧.ព្រះសង្ឃនាយក ស្ដីទី

## ហ៊ី ជា

## គណៈធម្មយុត្តិកនិកាយ

-ព្រះសង្ឃនាយកស្ដីទី **ហ៊ី ជា** បានសម្ភពនៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៤៤៧ គ.ស ១៩០៥ ក្នុងសង្កាត់ស្វាយធំ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

-ព្រះជន្មបាន៩វស្សា ព្រះមាតាបាននាំទៅនៅវត្តសំរោងពេជ្រ បន្ទាប់មកទៅនៅវត្ត ព្រៃពោន ក្នុងសំណាក់ព្រះគ្រូចៅអធិការព្រះនាម **រ័ត្ន** គណៈធម្មយុត្ត ក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

-នៅក្នុងវត្តព្រៃពោន បាន១ឆ្នាំ បានចេញមកនៅវត្តបទុមវតីរាជវរារាម សង្កាត់ លេខ២ ក្រុងភ្នំពេញ ។ មិនយូរប៉ុន្មាន បានបព្វជ្ជាជាសាមណេរ ក្នុងសំណាក់សម្ដេចព្រះមង្គលទេពាចារ្យ គណៈធិបតីសិរីព្រះសង្ឃនាយក ព្រះនាម **ស៊ុក** ក្នុងព្រះជន្ម១៦វស្សា ព.ស ២៤៦៥ គ.ស ១៩២១ ។

-ព្រះជន្ម២១វស្សា ឆ្លូវ ព.ស២៤៦៩ គ.ស ១៩២៥ ព្រះអង្គបានបំពេញឧបសម្បទា ជាភិក្ខុភាវៈ ក្នុងសំណាក់ព្រះញាណវីរិយៈ **ឡុង** ជាព្រះឧបជ្ឈាយ៍បាននាមបញ្ញតិថា **ភុទិញ្ញាណោ** ។

-ព្រះអង្គបានទទួលសមណស័ក្តិ ជាព្រះព្រហ្មមុនី ព្រះមហាព្រះវីរវង្សាចារ្យ ព្រះធម្មឧត្តម ។ ក្រោយមកព្រះអង្គបានឡើងជាព្រះពុទ្ធាចារ្យ រាជាគណៈថ្នាក់ឯក ។

-នៅក្នុងឆ្នាំថោះ១៩៧៥ ប៉ុល ពត បានបញ្ជាមិនឱ្យមនុស្សម្នាក់រស់នៅក្រុងភ្នំពេញចេញទៅក្រៅទាំងអស់ ។ នៅពេលនោះ ព្រះពុទ្ធាចារ្យ **ហ៊ឺ ជា** ទើបតែទទួល ឋានន្តរស័ក្តិ ជាព្រះសង្ឃនាយក ស្ដីទី មិនទាន់បាន១សប្ដាហ៍ផង ។

-ព្រះអង្គបាននិមន្តដល់ខេត្តស្វាយរៀង ប៉ុល ពត បានផ្សឹកព្រះអង្គអោយទៅជាមនុស្សធម្មតាវិញ ។ ក្រោយមក ក្មួយបានអញ្ជើញគាត់ ឱ្យមករស់នៅក្នុងភូមិកំពង់ ភ្នំក្នុង ។ ព្រះអង្គបានចូលទីវង្គតនៅគ.ស១៩៨៦ ព្រះជន្ម៨២ឆ្នាំ នៅភូមិកំពង់ភ្នំក្នុង ស្រុកលើកដែក ខេត្តកណ្ដាល ។



សម្តេចព្រះសុគន្ធាធិបតី គណៈធម្មយុត្តិកនិកាយ

**បួរ គ្រី**

# ៨. សម្តេចព្រះសុគន្ធាធិបតី

# ថ្ង ត្រី

# ព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ

# ព.ស ២៥៣៥-គ.ស ១៩៩១

-ព្រះអង្គប្រសូត នៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំវក ព.ស២៤៨៨ ត្រូវ នឹងថ្ងៃ១១ ខែមករា ឆ្នាំ១៩៤៤ នៅក្នុងឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ ព្រះមាតាព្រះនាម ជា ជួន ព្រះបិតាព្រះនាម ប៊ូរ វ៉ាន ។

-ព្រះអង្គព្រះជន្មបាន ៧ឆ្នាំ ព្រះមាតា បិតា បាននាំកុមារ ថ្ងៃ ត្រី អោយរៀន អក្សរ និងលេខនពន្ត នៅសាលាបឋមសិក្សាទក្ខិណសាលា ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។

-នៅឆ្នាំ កុរ ឯកស័ក ព.ស២៥០៣ គ.ស ១៩៥៩ ព្រះអង្គបាន ប្រឡងចូលរៀន នៅវិទ្យាល័យបាត់ដំបង ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ លុះដល់ឆ្នាំ ថោះ គ.ស ១៩៦៣ ព្រះអង្គបានប្រឡង ជាប់សញ្ញាប័ត្រ មធ្យមសិក្សា(ឌីប្លូម) ។

-នៅក្នុងឆ្នាំថោះ គ.ស១៩៦៣នោះដែរ ព្រះអង្គចេះតែមើលឃើញ ភេទបព្វជ្ជាជាភេទប្រសើរថ្លៃថ្លា ។ ព្រះអង្គបានលាមាតាបិតានិងក្រុមញាតិ ទៅបំពេញភេទបព្វជ្ជា ជាសាមណេរ និឧបសម្បទជាភិក្ខុភាវៈ នៅវត្ត បុប្ផារាម ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។

-បន្ទាប់ពីបព្វជ្ជារួច ព្រះអង្គបានខំរៀនសូត្រព្រះធម៌ និងព្រះវិន័យ ឯវិជ្ជាផ្លូវលោក ព្រះអង្គមិនសូវមានបញ្ហាកង្វល់ឡើយ ។

-បន្ទាប់មក ព្រះអង្គបានគង់នៅវត្តបុប្ផារាម និងវត្តបទុមវតី ដើម្បីរៀនភាសាបាលី ។ ព្រះអង្គបានរៀនប្រែគម្ពីធម្មបទ និងមង្គលទីបនីចប់សព្វគ្រប់ ។

-នៅឆ្នាំថោះ សប្តស័ក ព.ស២៥១៩ គ.ស១៩៧៥ ព្រះអង្គបានរត់ភៀសសឹកទៅស្នាក់នៅប្រទេសថៃ ក្នុងឋានៈជាជនភៀសខ្លួននយោបាយ ដើម្បីឆ្លងកាត់ទៅប្រទេសបារាំង ។

-នៅថ្ងៃទី១៦ ខែកុម្ភៈ គ.ស ១៩៨០ ឆ្នាំវក ទោស័ក ព្រះអង្គបានកសាងវត្តខេមរារាម ពុទ្ធិកសមាគមខ្មែរ នៅប្រទេសបារាំង ។

-នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៥ ព្រះអង្គបានរៀបចំធ្វើពិធីសម្ពោធឆ្លងវត្ត ខេមរារាមពុទ្ធិកសមាគមខ្មែរ ក្រោមព្រះរាជអធិបតីភាពព្រះករុណាជាអម្ចាស់ សម្តេចព្រះ **នរោត្តម សីហនុ** ។

-នៅពេលនោះ ព្រះករុណាជាអម្ចាស់ បានថ្វាយព្រះកិត្តិយសប្រគេនព្រះតេជគុណ **ម៉ឺរ គ្រី** ជា **ព្រះសុវណ្ណធម្មខេមរសាសនវង្ស** ប្រគេនស្រោចព្រះសុគន្ធវារីជាព្រះគ្រូ ចៅអធិការ វត្តខេមរារាម ។

-នៅថ្ងៃចន្ទ័ ៦រោច ខែអស្សុជ ឆ្នាំរោង ព.ស ២៥៣២ ត្រូវនឹងថ្ងៃ៣១ ខែតុលា គ.ស ១៩៨៧ **សម្តេចព្រះ នរោត្តម សីហនុ** ទ្រង់បានប្រទាន ព្រះបរមងារ ជា **សម្តេចព្រះគ្រូ** ។

-នៅថ្ងៃសៅរ៍ ១កើត ខែមិគសិរ ឆ្នាំមមែ ព.ស ២៥៣៥ ត្រូវនឹងថ្ងៃ០៧ ខែធ្នូ គ.ស ១៩៩១ **សម្តេចព្រះ នរោត្តម សីហនុ** ទ្រង់បានប្រទានព្រះបរមងារ ជា **សម្តេចព្រះសង្ឃរាជ គណៈធម្ម យុត្តិកនិកាយ** ។



# ផ្សាយចេញពី

# វត្តអង្គប្រិយសីរីមានជ័យ

## ឃុំកំពង់សំរោង ស្រុកកំពត ខេត្តកំពត

## ចែកជូនជាធម្មទាន